# សៀវភៅគតិលោក
## ភាគ ទី៥



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

ChanBoKeo.com

# និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានសត្វចចក១ ទៅសុំទុងជាមិត្រ ទុងនោះសោតក៏មានចិត្តស្រឡាញ់ចចកជាមិត្រមេត្រី ប៉ុន្តែសត្វទាំងពីរនោះជាសត្វទាំងពីរនោះ ជាសត្វស្រឡាញ់គ្នាតែកិរិយាខាងក្រៅ ឯក្នុងចិត្តនោះ គិតតែងកោងគ្នាដោយក្តីមច្ឆរិយៈកំណាញ់របស់រៀងខ្លួន ៗ ថ្ងៃមួយចចកនិយាយបបួលទុងថា "មិត្រអើយ! ថ្ងៃនេះខ្ញុំសូមអញ្ជើញមិត្រឯងទៅស៊ីលៀងនៅផ្ទះខ្ញុំតាមកាល" ទុងក៏ព្រមទៅ ៗ មុននឹងរៀបភោជនាហារលៀងនោះ ចចកគិតថា "អញនឹងមិនឲ្យអាទុងវាចឹកស៊ីរបស់អញបាន" គិតហើយចចករៀបបាយចំណីដាក់ក្នុងភាជនៈ មានផ្ទៃរាបប្រៀបដូចថាសរាប ហើយប្រាប់ទុងថា "អញ្ជើញមិត្រពិសាឲ្យសប្បាយ" ឯទុងជាសត្វចំពុះវែង ចឹកចំណីអាស្រ័យពុំបានដោយទើសនឹងថាសរាបរឹង ម្ល៉ោះហើយក៏ឈប់ឈរ នៅស្ងៀមទៅឯចចកមាត់វាទាលវាស៊ីបាន ស៊ីបណ្តើរនិយាយថា "ម្តេចសំឡាញ់មិនពិសារទៅ" ទុងស៊ីពុំបាន ឯចចកក៏បេះតែស៊ីទាល់តែឆ្អែតហោង ៗ

ឯទុងនោះ កាលរួចការស៊ីលៀងហើយក៏ហើរមកកាន់លំនៅនៃអាត្មា កើតក្តៅចិត្តនឹងចចករៀបអាហារដាក់មិនឲ្យខ្លួនស៊ី



បាន ទើបគិតថា "ចាំអញទៅបបួលអាភៀនកោងមកស៊ីលៀងនៅផ្ទះអញវិញ អញនឹងរៀបអាហារចំណីដាក់ កុំឲ្យអាចចកនោះវាស៊ីបាន" គិតហើយទៅបបួលចចកមកស៊ីលៀងនៅផ្ទះអាត្មាចចកក៏មក ៗ ទុងក៏រៀបអាហារចំណីនោះ ដាក់ក្នុងដបមានមាត់តូច ដែលខ្លួនអាចបញ្ចូលចំពុះទៅក្នុងដបចឹកយកចំណីបាន ហើយហៅទៅចចកថា "អញ្ជើញមិត្រចូលពិសាជាមួយគ្នាទៅ" ឯចចកនោះមាត់ធំលូកមិនចុះទៅក្នុងដបនោះឡើយ រកឱកាសនឹងស៊ីពុំបាន ក៏អង្គុយស្ងៀមនៅ គិតឃើញថាទុងគេកែខ្លួនគេហើយ ព្រោះពីថ្ងៃមុន ឯងក្លែងដាក់អាហារនឹងថាសរាប មិនឲ្យវាស៊ីបាន ឥឡូវវាក្លែងដាក់អាហារក្នុងដបមាត់តូចដល់រួចការលៀង ក៏លាទុងវិលទៅកាន់លំនៅនៃខ្លួនវិញហោង ៗ

រឿងនិទាននេះ មានគតិប្រៀបដូចម្តេចចូរឯងប្រៀបប្រាយទៅមើល ៗ

កូនសិស្សតបថា រឿងនេះបានគតិខាងមិត្តតែមាត់ចិត្តមិនបានជាមិត្តឡើយ ឯកិរិយាក្លែងពុំចង់ឲ្យភៀនឬភ្ញៀវអាស្រ័យនោះ ដូចអ្នកខ្លះរៀបបាយឲ្យភ្ញៀវបរិភោគដាក់ស្វាយទុំទាំង

មូលតែកាំបិតពុំបានដាក់ឲ្យចិតឡើយ ឬមួយដាក់ហ៊ីបស្លាឲ្យស៊ី ដាក់ស្លាស្លឹងទាំងមូល តែប្រណាកពុំដាក់ យ៉ាងនេះឲ្យចូលចិត្តថា ដូចតម្រាទុងនឹងចចកនេះឯង ។

### ចប់តម្រាគតិមិត្រកោងមិត្រទី៨

## និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានសត្វទុង១ ជាសត្វកាន់សក្កាយទិដ្ឋី ថ្ងៃមួយចេញស្វែងរកចាប់ត្រីជាអាហារ លុះហែលទៅបានឃើញត្រីក្អិត១ ហែលនៅខាងមាត់ខ្លួនទុងនោះក៏ចឹកត្រីក្អិតនោះបាន ទើបមកគិតថា អាត្មាអញនេះជាបក្សីរូបធំ ត្រូវតែបរិភោគត្រីធំៗយ៉ាងត្រីរស់ ត្រីឆ្តោ ត្រីប្រាជាដើមនោះ ទើបសមនឹងសក្តិយសរូបអញនេះ អាត្រីក្អិតរូបតូចមួយនេះ មិនសមគួរនឹងរូបអញឡើយ គិតហើយទុងក៏លែងចោលត្រីក្អិតនោះបង់ហើយហែលទៅមុខទៀត លុះដល់ទី១ បានយល់ត្រីចង្វា ១ ហែលមកខាងមុខ ទុងនោះចឹកបានលើកឡើងគិតទៀតថា ត្រីចង្វានេះក៏តូចណាស់ពុំសមគួរនឹងអញជាបក្សីធំនេះឡើយ គិតហើយក៏លែងត្រីចង្វានោះចោលបង់ ហើយហែលទៅមុខទៀតបានយល់ត្រីចង្វាភ្លៀង១ ទុងក៏ចឹកបានលើកឡើងនឹងស៊ី ក៏គិតថាត្រីចង្វារ



ភ្លៀងនេះ រូបតូចពេកណាស់ពុំគួរនឹងរូបអញជាធំគិតហើយក៏លែងត្រីនោះចោលបង់ ហើយខំហែលទឹកស្វែងទៅមុខទៀត ស្វែងទៅៗរកត្រីពុំបាន ពេលសោតក៏ទន់ទាបល្ងាចនឹងផុតពេលស្វែង ទុងនោះឯងកើតឃ្លានអាហារមហិមាខំស្វែងរកអាហារពុំបានឡើយ ម្លោះហើយទុងកើតទុកខមុខសុបសៅ កើតក្តៅចិត្តគិតស្តាយអាហារដែលខ្លួនរកបានអំពីព្រឹកនោះថា ស្តាយអើយ សែនស្តាយត្រីក្អិត១ នោះបើប្រសិនជាបរិភោគមកល្មមកល់ខ្លះ ស្តាយត្រីចង្វា បើប្រសិនណាជាស៊ីមកក៏ជាការកល់ឡើងរួមនឹងត្រីក្អិតជាន់មុននោះ ស្តាយត្រីចង្វាភ្លៀងមួយ បើប្រសិនណាជាស៊ីមកទៀត ក៏ជាការផ្សំគ្នានឹងត្រីជាន់មុនបានកល់ឡើងច្រើនល្មមបន្ទោបង់ក្តីឃ្លាននេះបាន ឥឡូវនេះដល់ពេលឃ្លានក៏ខ្លាំងពេលថ្ងៃនឹងស្វែងទៅទៀត ក៏ផុតតែត្រឹមនេះ អញនេះហៅពេញជាគិតខុស មិនសន្សំត្រីតូចៗស៊ីផ្សំគ្នាគិតប្រមាថថាអាតូចៗមិនសមនឹងខ្លួន ចាំរកត្រីធំៗឲ្យសមសក្តិយសខ្លួន ដល់មិនបានត្រីធំក៏អត់ទៅតម្រានេះ គឺអាធំក៏ខូច អាតូចក៏ខាត បានក្តីទុក្ខវេទនាដោយអត់អាហារនោះហោង ។

អើរឿងនេះបានជាគតិប្រៀបប្រាយទៅយ៉ាងណាឯងថា

ទៅមើល ៗ

កូនសិស្សតបថា គតិនេះបានដូចកូនអ្នកកាន់ត្រកូលទៅរៀនវិជ្ជាចេះមកអំពីប្រទេសក្រៅ ហើយចូលមកប្រទេសខ្លួន រាជការបានតាំងឲ្យធ្វើការបើកប្រាក់ខែឲ្យត្រឹម ១០-២០រៀលជាដើម ខ្លួនមិនទទួលធ្វើកាន់ខ្លួនថា ខ្លួនជាកូនត្រកូលធំ ប្រាក់ខែប៉ុណ្ណឹងមិនសមនឹងចំណេះនិងត្រកូលខ្លួន គិតចាំយកប្រាក់ខែដល់ ៨០-៩០ ឬ ១០០ ជាទុនធំតែម្ដង ដូចទូងចាំយកត្រីរ៉ស់ ត្រីឆ្ដោ ពោប្រាតែម្ដងដល់រកមិនបានកើតខាតខាន កើតស្ដាយទុនតូចដែលគេបំរុងឲ្យក្នុងកាលមុននោះឯង ៗ

មួយទៀត បានដូចលោកចៅអធិការឬលោកមហាអាចារ្យ កាន់ខ្លួនថាធំ គិតថាអាត្មានេះសមតែគេនិមន្តឡើងគ្រែទេសនាសង្គាយនា ឬឆាកមហាបង្សុកូល ទស់បន្ទុង គ្រងកឋិន ក៏ឯការតូចៗដូចយ៉ាងគេនិមន្តសូត្រមន្ត ឬបង្សុកូលខ្មោចជាដើមនេះ មិនសមគួរដល់អាត្មាជាធំឡើយ កាន់ដូចយ៉ាងទុងនេះឯង ៗ

**ចប់តម្រាគតិរកស៊ីមិនសន្សំពីវត្ថុតូចៗទី៨**

## និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានសត្វកណ្ដុប ១ ហើរទៅទំស៊ីស្លឹកនូវផ្លែផ្កានៃដើមសង្កែ



ដុះនៅវាលស្រែក្រៅ១ លុះបរិភោគឆ្អែតហើយ ក៏ហើរទៅព្រៃភ្នំ ចុះទំលើមែកសង្កែភ្នំ១ ដុះនៅក្រោមឈើធំទាំងឡាយ លុះដល់ពេលឃ្លានអាហារក៏ហើរឆ្វៀលដើមសង្កែភ្នំ ដើម្បីរកមើលស្លឹក មើលផ្លែផ្កានិងបរិភោគ ហើររកពុំឃើញមានស្លឹកនូវផ្លែផ្កាឃើញមានតែដើមខ្ពស់ដូច្នោះ កណ្ដុបនោះក៏និយាយថា ដើមសង្កែដែលដុះឯវាលស្រែនោះ គេមានមែកត្រសុំត្រសាយបរិបូណ៌ដោយផ្លែផ្កា មានស្លឹកស្រោបជិតជុំដើម ជាទីប្រជុំនៃសត្វកន្លង់ កណ្ដុប អណ្ដើក មាសទាំងឡាយអាស្រ័យបរិភោគបាន អើប្រស្ដែងសង្កែភ្នំនេះ ហេតុអ្វីក៏ពុំមានស្លឹកបែកផ្លែផ្កាដូចគេ មានតែដើមដុះលូតខ្ពស់រៀវចុងយ៉ាងនេះ រកតែស្លឹកនិងស្រោបខ្លួនគ្មាន ៗ

ឯសង្កែនោះក៏ប្រាប់ថា "ឱអ្នកអើយ! ដើមខ្ញុំនេះដុះនៅក្រោមឈើធំ ក៏វិស័យឈើធំទាំងឡាយមានដើមផ្ចឹករាំងឈើទាលជាដើមនោះ គេជាតិឈើភ្នំប្រកបដោយខ្លឹមខាងក្នុង គេក៏លូតបែកមែកត្រសាយត្រសុំ ដោយភាពគេជាឈើភ្នំ តែខ្ញុំឯងនេះជាជាតិឈើឥតខ្លឹម ហើយមកដុះនៅខាងគេ តាំងលូតតាមគេទៅ ទាល់តែរកស្លឹកពុំមានយ៉ាងនេះឯង ៗ

ឯកណ្ដូប ក៏និយាយតិះដៀលដើមសង្កែនោះផ្សេងៗហើយ សរសើរដើមសង្កែ ដែលដុះនៅតាមវាលស្រែផុតអំណាចឈើធំនៅគ្របសង្កត់ពីខាងលើ ពុំបានលូតតាម ត្រាប់តាមឈើធំឲ្យបង់ស្លឹកផ្លែផ្កាដុះតាមធម្មតាខ្លួនឯង តាមតែចិត្តចង់បំបែកមែកតូច ធំតាំងស្លឹកផ្កាផ្លែបិទបាំងខ្លួនយ៉ាងណាៗ ក៏ឥតមានទើសទាល់អ្វីមួយឡើយ កណ្ដូបពោលពាក្យដូច្នោះហើយក៏ហើរទៅកាន់លំនៅនៃខ្លួនវិហោងៗ

ចុះរឿងនេះ បានសេចក្ដីជាគតិយ៉ាងណាចូរអត្ថាធិប្បាយទៅមើល?ៗ

កូនសិស្សតបថា ឯដើមផ្ទឹកវាំងឈើទាលនោះ ជាវុក្ខជាតិមានខ្លឹម ដុះឡើងក៏លូតខ្ពស់តាំងបែកមែកតូចធំ ព្រមទាំងស្លឹកផ្លែផ្កាបាន សមដោយជាតិជាឈើធំ នេះបានគតិដូចមនុស្សអ្នកមានសម្បត្តិ មានយសស័ក្តិ មានប្រាក់ខែបរិបូណ៌បើគេស្លៀកពាក់គ្រឿងតែខ្លួន ឬគេបរិភោគភោជនាហារយ៉ាងឧត្តមក៏សមរបស់គេឥតមានក្ដីខាត់ ឯជាតិដើមសង្កែឬប្របួយ លាជផ្ទុះជាដើមនោះ ជាជាតិឈើស្រែ ឈើក្រៅ សមគួរតែដុះវាលស្រែក្រៅ ដែលផុតអំពីម្លប់ឈើធំ ទើបអាចតាំងមែកស្លឹកផ្លែ



ផ្កាបរិបូណ៌ទៅបានបើទៅដុះនៅខាងឈើធំហើយ ក៏ពុំអាចតាំងមែកស្លឹកផ្លែផ្កាបានឡើយ នេះបានគតិដូចមនុស្សអ្នកឥតចំណេះឥតទ្រព្យសម្បត្តិ ហើយត្រាប់តាមអ្នកមានសម្បត្តិ មានយស ទិសគ្រឿងតែងខ្លួន ឬអាហារខ្ពស់ប្រើកិរិយាយ៉ាងអ្នកធំលូតតាមអ្នកធំ ម្ល៉ោះហើយក្ដីក្រក្ដីលំបាក់ ក៏កើតដល់ប្រាណ មានឧបមេយ្យដូចដើមសង្កែត្រាប់តាមឈើធំនោះឯងៗ

ឯដើមសង្កែ ដែលដុះដោយវាលស្រែបរិបូណ៌ដោយមែកស្លឹកផ្លែផ្កានោះ បានគតិដូចមនុស្សអ្នកឥតចំណេះវិជ្ជាការខ្សត់ក្រ តែទៅប្រព្រឹត្តដោយការរកស៊ីធ្វើស្រែចំការជួញប្រែលក់ដូរ ឱស្សាហ៍សន្សំទ្រព្យសម្បត្តិ ទុកដាក់ពុំហ៊ានចែកចាយដោយការពុំគួរចាយនោះ ទ្រព្យសម្បត្តិកើតមានឡើង ដូចដើមសង្កែដុះដោយវាលស្រែនោះឯងៗ អ្នកស្រែចំការមានទ្រព្យសម្បត្តិ ជាទីឲ្យមហាជនសរសើរៗ

អ្នកក្រុងពិតតែឥតទ្រព្យសម្បត្តិ ប៉ុន្តែប្រឹងលូតតាមអ្នកធំដូចដើមសង្កែដុះក្បែរភ្នំ ជាទីឲ្យកណ្ដូបមេអំបៅ អណ្ដើកមាសតិះដៀលនិន្ទាៗ អ្នកមានបញ្ញាគួរពិចារណាយកជាគតិលោកយោគឲ្យឃើញមនុស្សត្រាប់អ្នកធំមាននៅក្នុងសម័យឥឡូវនេះៗ

**ចប់គតិអ្នកលូតអស់ស្លឹកទី ៩។**

មានក្អែក១ បានឃើញខ្មោចឆ្កែ១ អណ្តែតទឹកក៏ចុះទំចឹក ស៊ីបណ្តែតទៅតាមខ្សែទឹក ចេញទៅដល់កណ្តាលសាគរ ក្អែកនោះភ្លើនស្មារតី ពុំបានគិតនឹងហើរវិលមកកាន់ទីគោកឡើយ៕

លុះស៊ីឆ្អែតហើយ ក្អែកនឹងគេចហើរមកទីគោកពុំបានព្រោះខ្មោចឆ្កែនោះ អណ្តែតទៅកណ្តាលមហាគង្គា ផុតមើលត្រើយពុំយល់ ក្អែកនោះហើរមកមិនដល់គោក ក៏គាំងស្លាប់អស់កំលាំងធ្លាក់លិចចុះក្នុងគង្គា ដល់នូវក្តីមរណៈសូន្យជីវិតហោង៕

រឿងនិទាននេះ បានគតិប្រៀបប្រាយអត្ថាធិប្បាយដូចម្តេច?

កូនសិស្សតបថា រឿងនេះបានគតិដូចនិទានសត្វចចកដែលលោភខ្លាំង ចូលទៅស៊ីគ្រឿងក្នុងពោះនៃខ្មោចដំរីសារ បាននូវសេចក្តីទុក្ខវេទនា ព្រោះឥតសតិបញ្ញានឹងពិចារណាឲ្យយល់ហេតុផល ហៅថាមិនដឹងប្រមាណក្នុងការបរិភោគភោជន អ្នកប្រាជ្ញគប្បីចូលចិត្តហោង៕

**ចប់តម្រាគតិលង់ដោយលោភទី ១០។**

មានលោកសង្ឃអង្គ១ ជាចៅអធិការ នាំក្មេងពីរនាក់ជាកូនសិស្សចេញចាកអារាមទៅព្រៃ ដើម្បីនឹងទិញឈើធ្វើកុដិ កូនសិស្សក៏ស្ពាយកញ្ចប់ចង្ហាន់យកទៅដើម្បីឆាន់ពេលថ្ងៃត្រង់



លុះទៅដល់ត្រពាំង១ មានទឹកដ៏ថ្លាស្អាត មានរុក្ខជាតិដុះជិតជុំ ម្លប់ត្រសុំសប្បាយ ជួនពេលថ្ងៃត្រង់លោកសង្ឃនោះ ចូលឈប់ប្រារព្ធនឹងឆាន់បាយ ទើបក្មេងទាំង២ នាក់ ក៏ចាត់ចែងយកចង្ហាន់កញ្ចប់នោះប្រគេន ឯម្ហូបនោះមានតែត្រីកន្ត្រប់អាំង១៕ លោកចៅអធិការក៏តាំងឆាន់ ឯក្មេងទាំង២ នាក់វាអង្គុយគាល់លោកឆាន់ វានឹកក្នុងចិត្តវាថា លោកគ្រូប្រហែលជាឆាន់ត្រីកន្ត្រប់នេះ តែ១ចំហៀងខាងលើឯចំហៀងខាងក្រោមសោត គង់តែលោកនឹងទុកឲ្យយើងកូនសិស្សពីរនាក់ ក្មេងគិតដូច្នោះហើយវាក៏ខ្សឹបប្រាប់គ្នាវាឲ្យដឹងជាសញ្ញា៕

ឯលោកចៅអធិការ លុះឆាន់បាយអស់ត្រីអាំង១ ចំហៀងហើយក៏នៅឆ្ងាញ់ ទើបប្រែត្រឡប់ត្រីកន្ត្រប់ឆាន់ខាងចំហៀងក្រោមទៀត៕

ឯកូនសិស្ស ឃើញលោកគ្រូត្រឡប់ត្រីអាំងឆាន់ចំណែកខ្លួនវាដូច្នោះ វាក៏នាំគ្នាក្រោកឈរឡើងហើយវាថា វ៊ុយ គ្នាយើងឥឡូវនេះផែនដីប្រែហើយ នៅផងពុំបានទេ អាដែង៕

ក្នុងខណៈនោះមានក្របីព្រៃ១ ដើរមកផឹកទឹកក្រពាំង បានឃើញមនុស្សនៅនោះ វាក៏បោលចូលមកនឹងវែធ៕

ឯកូនសិស្សទាំងពីរនាក់បានឃើញក្របីព្រៃបោលដេញមក ដូច្នោះ ទើបវានាំគ្នារត់ចោលលោកគ្រូ ហើយវាឡើងដើមឈើ ត្រាតែដល់ចុង ផុតអន្តរាយនឹងក្របី ឯលោកចៅអធិការកំពុងតែឆាន់ឆ្ងាញ់ស្រាប់តែក្របីព្រៃមកជិត ក៏ភិតភ័យតក់ស្លុត ក្រោកឡើងនឹងរត់ ហើយស្រែកហៅកូនសិស្សឲ្យជួយដោយទួសទានណាស់ ៗ

ឯកូនក្មេងនៅលើចុងឈើវានាំគ្នាស្រែកទៅថាផែនដីប្រែហើយ នរណាឡើងនឹងទៅជួយត្រីកន្ត្រប់តូចមួយ ឆាន់អស់នៅសល់តែឆ្អឹង ចូលលោកគ្រូខំប្រឹងរត់ទៅតែឯង តាមយថាកម្មវៀងខ្លួនចុះយើងមិនចុះទៅជួយទេ ៗ

ឯលោកនោះ រត់មិនរួចពីក្របីៗ ក៏វែធដល់នូវមរណកាល កណ្ដាលព្រៃនោះហោង ៗ

រឿងនិទាននេះ បានសេចក្ដីជាគតិយ៉ាងណាចូរថាទៅមើល?

កូនសិស្សតបថា រឿងនិទាននេះបានគតិដូចពាក្យសុភាសិតច្បាប់ចាស់ថា "បានស្ករនឹងទឹកឃ្មុំពួនក្នុងផ្ទះស៊ីម្នាក់ ឯង" ៗ បុគ្គលទាំងឡាយក្នុងលោកនេះ សឹងមានអាហារជាថ្នាំកែរោគឃ្លាន គឺតំលានជារោគធំបំផុត បុគ្គលណាចង់រស់តែឯង មិនគិតដល់អ្នក



ដទៃផង បុគ្គលនោះលុះមានក្ដីភ័យឯណាមួយមកដល់ខ្លួនហើយ នឹងស្រែករកឲ្យគេជួយ គេក៏ពុំមកជួយឡើយហៅថាពុំដឹងប្រមាណក្នុងការបរិភោគ ៗ អ្នកមានបញ្ញាគួរត្រិះរិះគិតទៅទៀតចុះ ៗ

**ចប់តម្រាគតិបរិភោគអាហារមិនគិតគេទី ១១**

## តម្រាប្រែផែនដីក្របីវែធស្លាប់ អញ្ជើញអ្នកស្ដាប់ កុំត្រាប់យកជាគតិ។

និទានព្រះមហិស្សរាធិបតី គឺព្រះឥស្វរសាងលោក កាលសាងលោកសំរេចហើយ ព្រះឥស្វរហៅពួកសត្វចតុប្បាទ អបាទ ពហុបាទ ទាំងឡាយចូលមកកាន់ទីប្រជុំ ដើម្បីនឹងសួរសេចក្ដីសុខទុក្ខសព្វសត្វ តើសត្វពួកណា គាប់ចិត្តនឹងរូបកាយខ្លួនឬពុំគាប់ចិត្តនឹងរូបកាយខ្លួនទេ នឹងកែប្រែជាថ្មីតាមក្ដីប្រាថ្នារបស់សត្វលោកទាំងពួង ៗ

កាលទ្រង់សួរនោះ គឺទ្រង់សួរស្វាជាមុនថា "ហៃចៅពានររូបកាយបាងងដែលយើងសាងឲ្យ មានអវយវៈយ៉ាងនេះ សព្វថ្ងៃនេះតើចៅគាប់ចិត្តពេញចិត្តហើយឬៗ នៅមានក្ដីទាស់ត្រង់ណាខ្លះ ចូរចៅថាទៅមើលនឹងកែប្រែជាថ្មីទៀត" ៗ

ឯពានរមើលទោសឯងមិនយល់ សំគាល់ថារូបខ្លួនឥតទាស់

ទើបទូលព្រះឥសូរថា "សូមទានល្អងធូលីព្រះបាទសាងរូបកាយខ្ញុំជាស្វានេះ ពេញជាស្រួលណាស់ហើយ មានទាំងដៃជើងឡើងដើមឈើបានកកបកំលាំង លោតចេះផ្លែឈើអាស្រ័យបានដោយងាយ ទាំងឥតកិច្ចការធ្វើស្រែចំការជួញប្រែដូចយ៉ាងមនុស្សនោះឡើយ ព្រះអង្គសាងរូបកាយខ្ញុំនេះគាប់ចិត្តខ្ញុំហើយ មិនបាច់កែប្រែឲ្យខ្ញុំទៀតទេ បើព្រះអង្គចង់កែនោះ សូមមេត្តាកែសត្វខ្លាឃ្មុំវិញ ព្រោះរូបវាមិនសមរម្យល្អទេ គឺមុខនោះប្របូញ រោមខ្មៅជិត ឥតមានកន្ទុយនឹងបត់ ឃើញអាក្រក់លើសគេនានា សូមមេត្តាកែវាជាថ្មីចុះម្ចាស់"។ ព្រះឥសូរបានឮថាដូច្នោះក៏ត្រាស់ទៅខ្លាឃ្មុំថា "ហៃចៅអញ្ញាជាតិ រូបកាយចៅឯងដែលយើងសាងឲ្យយ៉ាងនេះ តើជាទីគាប់ចិត្តចៅឯងហើយឬៗ នៅទាស់ត្រង់ណាខ្លះ ចូរថាមកយើងនឹងកែឲ្យ?។

ឯខ្លាឃ្មុំមិនយល់ទោសខ្លួនក៏ឆ្លើយថា "រូបខ្ញុំនេះព្រះអង្គសាងឲ្យមានធ្មេញចង្កូមដ៏មុត ទាំងរោមខ្មៅជិតបិទស្បែកក្នុង កុំឲ្យសត្វតូចៗ មានមូសស្រាំងស្រួយជាដើមចូលយាយីបាន ហើយមានជើងទាំង៤ ប្រកបដោយក្រចកដ៏មុត អាចឡើងឈើព្រៃយកឃ្មុំអាស្រ័យជាភក្សាហារបាន ឥតមានក្តីកង្វល់រវល់ដោយការ



ធ្វើស្រែចំការ ដូចមនុស្សក្នុងលោកនេះឡើយ រូបខ្ញុំនេះពេញចិត្តខ្ញុំហើយ មិនបាច់កែទៀតទេ បើព្រះចង់កែ សូមកែរូបដំរីវិញចុះ ដ្បិតរូបដំរីនោះខ្ញុំយល់ថាទាស់ខ្លាំងណាស់ គឺរូបអីមានប្រមោយ១ ក្បាលធំភ្នែកតូច ត្រចៀកកំភ្លាងរូបរាងធំកោងមើលមិនសមសោះម្ចាស់"។

ព្រះឥសូរឮអញ្ញាថាដូច្នោះ ក៏សួរទៅកាន់ដំរីវិញថា "ចៅហត្ថី រូបកាយចៅដែលយើងសាងឲ្យយ៉ាងនេះតើគាប់ចិត្តចៅហើយឬៗ នៅទាស់ត្រង់ណាទៀត ចូរថាទៅមើល?។

ឯដំរីពុំឃើញទោសខ្លួន ទើបសួរថា "ព្រះអង្គសាងរូបខ្ញុំឲ្យមានកាយធំខ្ពស់លើសគេ ទាំងភ្លុកសោតក៏ល្អប្រើជាអាវុធបាន ទាំងកំលាំងហៅហាន អាចបាក់អាចព្រេចនូវសត្រូវឥតទើសទាល់ បរិភោគស្មៅជាអាហារ ឥតក្តីរវល់នឹងធ្វើស្រែកាប់ចំការដូចមនុស្សនោះឡើយ រូបខ្ញុំនេះគាប់ចិត្តខ្ញុំហើយ ព្រះអង្គមិនបាច់តែទៀតទេ ឯការដែលទាស់នោះ ឃើញទាស់តែសត្វឱដ្ឋ គឺរូបជាសេះ តែកវាវែងដូចជាកកុកឃើញមិនសំណំសមជាសត្វពាហនៈឡើយ"។

ព្រះឥសូរក៏ត្រាស់ទៅឱដ្ឋវិញថា "ម្តេចចៅឱដ្ឋរូបកាយចៅ

ឯងសព្វថ្ងៃនេះស្រួលបួលហើយឬៗនៅទាស់ត្រង់ណាខ្លះ ចូរថាទៅមើល យើងនឹងកែឲ្យ?។

សត្វឱដ្ឋក៏ឆ្លើយថា "ព្រះអង្គសាងរូបកាយខ្ញុំមានកវែង អាចអើតស៊ីស្លឹកឈើខ្ពស់ៗបាន ហើយមានកំលាំងខ្លាំងក្នុងការបន្ទុក អាស្រ័យស្មៅផឹកទឹកឆ្អែតហើយ អាចអត់បាន៧ ថ្ងៃមិនតោងអាស្រ័យក៏បានហេតុនេះ ខ្ញុំយល់ថា ព្រះអង្គសាងរូបកាយខ្ញុំនេះវិសេសណាស់ហើយ មិនចាំតែប្រែទៀតទេ សូមព្រះអង្គកែរូបត្រីអនន្តមច្ឆាវិញ ព្រោះត្រីនោះរូបធំណាស់មិនសមនឹងភាពជាជាតិមច្ឆាឡើយ"។

ព្រះឥសូរក៏សួរត្រីវិញ "ត្រីឆ្លើយថាព្រះអង្គសាងរូបខ្ញុំ មានកាយដ៏ធំលើសគេ អាចហែលហក់ក្នុងមហាសាគរសមុទ្រធំ ឥតក្តីកោតក្រែងនឹងរលកខ្យល់ព្យុះ នេះជាការស្រួលហើយ មិនចាំកែទៀតទេទាស់តែសត្វស្រមោច ព្រះអង្គសាងរូបតូចណាស់ទាបណាស់ គេដើរជាន់ពីលើបាន សូមព្រះអង្គកែវាទៀតចុះ"។

ព្រះឥសូរក៏សួរទៅស្រមោច ដោយការក្រែងមិនគាប់ចិត្ត ឯស្រមោចក៏ឆ្លើយថា "ព្រះអង្គសាងរូបខ្ញុំតូចនេះស្រួលពេកហើយ តែមានភ័យអន្តរាយមកដល់កាលណា ចង់រត់ជ្រកក្នុង



សម្រាមឬកាកអំពៅក៏ឥតទើស ឯខាងអាហារសោតក៏រកបានងាយតែបាយ ឬអង្ករ១ គ្រាប់ក៏ទទួលទានបានឆ្អែតបរិបូណ៌រូបកាយខ្ញុំនេះ ឃើញស្រួលលើសសត្វនានាក្នុងលោកនេះ មិនតោងចាំកែជាថ្មីទៀតទេ"។

ព្រះឥសូរ ឮសត្វប្រាប់ក្តីសុខចិត្តគ្រប់គ្នាដូច្នោះក៏ស្ងៀមនៅហោង។

និទានរឿងនេះ បានជាគតិយ៉ាងណាចូរឯងអត្ថាធិប្បាយទៅមើល?។

កូនសិស្សតបថា និទាននេះបានគតិដូចពាក្យសុភាសិតគឺច្បាប់ចាស់ថា "ពាក្យចាស់ពាក្យពីព្រេងទោសខ្លួនឯងមើលមិនយល់ ទោសគេតូចសោតសល់ មើលទៅយល់ប៉ុនទាំងភ្នំ"។

មួយទៀ មានគតិក្នុងលោកនីតិថា

តិលមត្តំ បរេសំវ
អប្បទោសញ្ច បស្សតិ
នាឡិកេរំបិ សទោសំ
ខលជាតោ ន បស្សតិ

បុគ្គលយល់ទោសអ្នកដទៃ តូចប៉ុនគ្រាប់ស្ពៃឬល្ងសគទោសខ្លួនប៉ុនដូងទាំងសំបក ដែររកវិះគន់គយមិនយល់ ។

តម្រាសត្វលោកទាំងអស់សឹងឃើញតែទោសគេត្រង់ទោសខ្លួនមើលមិនយល់ ដូចកលសត្វទាំងឡាយមានពានរជាដើម ដែលព្រះឥសូរសួររូបកាយរៀងខ្លួន សឹងឃើញតែរូបអ្នកដទៃទាស់ មិនត្រូវភ្នែកខ្លួនទាំងអស់ ឯត្រង់រូបកាយរបស់ខ្លួនឯង សឹងតែអួតថាល្អ ថាគាប់ចិត្ត ឥតក្តីទាស់អ្វីឡើយ ។ អ្នកប្រាជ្ញគប្បីពិចារណាទៅទៀតចុះ ។

**ចប់តម្រាឃើញតែទោសគេទី ១២**

មានបរមខត្តិយរាជមួយព្រះអង្គ ទ្រង់ព្រះនាមមហាចក្រាមហិសុរាធិបតី មានឫទ្ធានុភាពផ្សាយអាណាចក្រទូទៅទាំងសាកល ។

មានស្តេច១០១ នាំសួយសារដម្បារមាសចូលមកថ្វាយ ទោះស្តេចគ្រុឌ នាគ យក្ខ ទេវតានិងសត្វ សីហរាជ ព្យគ្ឃរាជ គោលៀងភា មហិសា ក៏សឹងចុះចូលមូលមកថ្វាយបង្គំ សុំជាផ្លូវព្រះរាជមេត្រីទាំងអស់ ។ គ្រាកាលនោះមានស្តេចស្រមោចខ្មៅ១ ចង់ឡើងទៅសុំថ្វាយផ្លូវព្រះរាជមេត្រី នឹងស្តេចនោះដែរ ។



ថ្ងៃមួយទើបស្តេចស្រមោចនាំពួកបរិវារអាត្មា ទៅកាន់ផ្ទះសេនាបតី ដល់ហើយក៏និយាយថា "អ្នកសេនាបតីខ្ញុំនេះ មានចិត្តស្រឡាញ់ព្រះករុណាជាម្ចាស់អ្នកឯងនេះណាស់ ខ្ញុំមកនេះដើម្បីថ្វាយខ្លួនសុំព្រះអង្គជាផ្លូវព្រះរាជមេត្រីផង ដូច្នេះអ្នកសេនាចូរមេត្តានាំប្រព្រឹត្តហេតុរបស់ខ្ញុំនេះ ចូលទៅក្រាបបង្គំទូលទ្រង់ជ្រាបជាមុន ព្រះអធ្យាស្រ័យតើជាទ្រង់ប្រោសព្រមឬពុំព្រម ដ្បិតខ្ញុំជាជាតិសត្វតូចទាប ក្រែងព្រះទ័យយល់ថាពុំសមគួរ" ។

ឯអគ្គមហាសេនាបតី បានស្តាប់ពាក្យស្រមោចដូច្នោះក៏ទទួលពាក្យទើបរៀបអាត្មាម្នីម្នាចូលទៅគាល់ព្រះបរមខត្តិយា ក្រាបទូលតាមពាក្យស្តេចស្រមោចនោះគ្រប់ប្រការ ឯព្រមហិសុរាឮថាស្រមោចចង់ចូលមកជាព្រះរាជមេត្រី នឹងព្រះអង្គដូច្នោះក៏ទ្រង់ខាត់ព្រះទ័យ ដោយសេចក្តីយល់ថា សត្វស្រមោចសង្ការជាសត្វថោកទាប មិនគួរនឹងរាប់អានទៅទទួលមេត្រីនឹងវា ឲ្យអាបព្រះកិត្តិយសព្រះអង្គគិតហើយទើបត្រាស់ថា "អាសត្វស្រមោចជាតិតូចទាបណាស់ យើងជាស្តេចធំពុំគួរនឹងទៅតាំងផ្លូវព្រះរាជមេត្រីនឹងវាឡើយ អ្នកឯងទៅប្រាប់វាចុះថាយើងមិន

ទទួលមេត្រីទេ យើងមេត្រីតែនឹងសត្វធំៗយ៉ាងរាជសីហ៍ជាដើម"។

ឯអគ្គមហាសេនាបតី ជាអ្នកមានបញ្ញាជ្រៅទើបក្រាបទូលទៅថា "ធម្មតានាយជាងឈើឬជាងទងសិងមានគ្រឿងដែកតូចធំសម្រាប់ធ្វើការការឯណាធំត្រូវប្រើគ្រឿងធំ យ៉ាងដែកធាបពន្លាកធំទៅ ការឯណាតូចល្អិតត្រូវប្រើគ្រឿងតូចៗទៅ ដូចយ៉ាងការរាជការរបស់ល្អងធូលីព្រះបាទសព្វថ្ងៃនេះ រាជការឯណាធំ ក៏ត្រូវប្រើយក្សឬគ្រុឌឬរាជសីហ៍ជាដើមទៅ បើរាជការឯណាតូចល្អិតដល់មក យើងត្រូវប្រើសត្វតូចៗ ទៅតាមការនោះដូចយ៉ាងសត្វស្រមោចក៏មានប្រយោជន៍ខ្លះដែរ មានរឿងនិទានក្នុងទសជាតក៏ គឺរឿងព្រះមហោសថបណ្ឌិតពោធិសត្វថា កាលនោះព្រះបាទវិទេសរដ្ឋរាជមានកែវបុរាណ ១ ជាគ្រឿងប្រដាប់រូប កែវនោះវែងមានរន្ធវៀចជាសណ្ឋានខ្ចៅបុរាណ គេបោះដាក់ខ្សែប្រើបានដល់យូរមក ខ្សែនោះចាស់រេចរឹលក៏ដាច់ចេញអំពីដួងកែវ និងរកអ្នកឯណាយកខ្សែដោតដាក់ដូចមុនវិញពុំបាន ព្រះបាទវិទេសរដ្ឋរាជប្រើរាជអាមាត្យ ឲ្យនាំយកកែវនោះទៅឲ្យព្រះពោធិសត្វដាក់ខ្សែ ឯព្រះមហាស



ថបណ្ឌិតមានបញ្ញាអាចដោតកែវនោះ គឺលោកយកខ្សែសូត្រមកវេញត្រាញ់ ហើយយកស្ករលាយលាបចុងខ្សែក្នុងរន្ធកែវនោះ លាបទឹកឃ្មុំដាក់ជានុយស្រមោច ឯស្រមោចទាំងឡាយកាលធុំក្លិនស្ករទឹកឃ្មុំហើយក៏នាំគ្នាចូលទៅក្នុងរន្ធកែវ ស៊ីស្ករទឹកឃ្មុំខាំទាញចុងខ្សែទៅតាមរន្ធវៀចចេញទៅម្ខាងបាន ទើបមហោសថបណ្ឌិតទាញខ្សែដោតកែវបុរាននោះបាន ហើយឲ្យនាំទៅថ្វាយព្រះបរមក្សត្រិយ៍ក្នុងព្រះរាជបុរីវិញ។ រឿងបុរាណមានមកយ៉ាងនេះ ហេតុដូច្នេះសូមព្រះអង្គទ្រង់ទទួលផ្លូវព្រះរាជមេត្រីនឹងស្ដេចស្រមោចនោះផងចុះ"។

ឯព្រះបាទមហិស្សរាធិបតី បានស្ដាប់ពាក្យសេនាបតីទូលនាំរឿងបុរាណ ជាគតិដូច្នោះស្ដេចក៏ព្រម ទើបត្រាស់ថា "អើអ្នកសេនាបតី បើដូច្នោះអ្នកទៅប្រាប់ស្ដេចស្រមោចនោះផងចុះ ថាយើងទទួលមេត្រីហើយ ឲ្យវាវិលទៅទីស្ថានវាចុះ មិនចាំឡើងមកគាល់យើងទេ បើយើងមានរាជភារត្រូវការក សឹមឲ្យឡើងមកគាល់"។

ឯលោកអគ្គមហាសេនាបតី ក៏ក្រាបថ្វាយបង្គំលាចេញចាកទីគាល់ ទៅថ្លែងសេចក្ដីនោះប្រាប់ស្ដេចស្រមោចៗក៏មានចិត្ត

ត្រេកអរដោយសមក្តីប្រាថ្នាទើបលាសេនាបតីនាំពួកពលទៅកាន់លំនៅនៃអាត្មាវិញហោង ។

លុះនៅមកមានកាលសម័យថ្ងៃមួយ ព្រះបាទមហិស្សរាធិបតីស្តេចផ្ទំលើព្រះទែនទី មានសត្វក្លីស១ វារចូលទៅក្នុងរន្ធព្រះភាណ៌នៃព្រះអង្គ ស្តេចក៏ទ្រង់ក្រោកចាកទីបន្ទំ ខំយកចង្កៀលឆ្កៀលចាក់យកក៏ពុំបាន វារឹតតែរុកទៅខាងក្នុងស្តេចក៏រឹងឈឺពន់ពេកណាស់ ដាស់សម្តេចព្រះទេវី នូវស្ត្រីព្រះស្នំក្រមការឲ្យជួយយកក្លីសនោះ ។

ឯអស់ស្ត្រីស្នំទាំងឡាយ មាននាងទេវីជាប្រធានសឹងភិតភ័យទីទៃៗ នាំគ្នាហៅពេទ្យហ្លួងមកប្រកបឱសថដាក់ចាក់ទៅ ក្លីសនោះក៏មិនចេញឡើយ ព្រះបរមខត្តិយរាជក៏រឹងរឹតតែឈឺខ្លាំងតាំងពីមជ្ឈិមយាមយប់ត្រាដល់បច្ចូសសម័យ ស្តេចក៏នឹកទៅដល់គ្រុឌ នាគយក្ខ គន្ធព្វ កុម្ភណ្ឌ រាជសីហ៍ នរសីហ៍ ឲ្យមកជួយព្រះអង្គ ។

ឯអស់ស្តេចទាំងឡាយមានស្តេចគ្រុឌជាដើមក៏មកកាន់ទីប្រជុំជំនុំគ្នា ដើម្បីនឹងគិតយកក្លីសនោះជាកោលាហល សឹងទញ់ទាល់តម្រិះប្រាជ្ញាទីទៃៗ ពុំមានអ្នកឯណាមួយនឹងអាចយកអាសាបាន ។



គ្រាកាលនោះ សេនាបតិនឹកទៅដល់ស្តេចស្រមោចៗ ក៏នាំពួកពលបរិវារអាត្មាមកកាន់ទីប្រជុំ ទើបសេនាបតីប្រាប់ថា "ព្រះករុណាជាម្ចាស់យើងមានទុក្ខ ដោយសត្វតូច ចូលទៅក្នុងព្រះកាណ៌នៃព្រះអង្គ អស់ពួកស្តេចនានាសឹងទញ់ទាល់ប្រាជ្ញាទីទៃៗ សេចក្តីនេះតើអ្នកឯងគិតកែយ៉ាងណាបាន យើងរាល់គ្នាអស់តម្រិះប្រាជ្ញាហើយ" ។ ស្តេចស្រមោចបានស្តាប់ដូច្នោះហើយក៏ទទួលយកអាសា ទើបប្រើស្រមោចខ្មៅពីរជាសេនាទាហានឲ្យចូលទៅក្នុងព្រះកាណ៌នៃព្រះមហិស្សរាធិបតី ឯស្រមោចទាំងពីរ ក៏នាំគ្នាចូលទៅខាំទាញយកក្លីសអំពីខាងក្នុងព្រះកាណ៌ចេញមកខាងក្រៅបានហើយបង្ហាញដល់ប្រជុំជន មានព្រះបានមហិស្សរាធិបតីជាដើម ឯបណ្តាប្រជុំជនទាំងឡាយ សឹងមានចិត្តត្រេកអរសាទរមហិមា នាំគ្នាសរសើរក្តីគាប់របស់ស្តេចស្រមោចនោះ ជាអនេកបរិយាយផ្សេងៗ ហើយនាំគ្នាថ្វាយបង្គំលាចេញទៅកាន់លំនៅនៃខ្លួនទីទៃៗ ។

រឿងនេះ បានគតិដូចបុគ្គលអ្នករាប់អានតែអ្នកមានយសស័ក្តិនូវអ្នកមានសម្បត្តិ ត្រង់អ្នកតូចពូជទាបឬញាតិសន្តានជាអ្នកក្រីក្រ ពុំរាប់អានឡើយ លុះដល់ខ្លួនមានកិច្ចការ ដូចមានអា

វាហមង្គលជាដើមដល់មកនឹងទៅពឹងរកអ្នកមានសម្បត្តិ មានយសស័ក្តិនោះមកឲ្យជួយរែកសែង ដងទឹក បុកស្រូវ ពុះឧសឯណាក៏បាន តោងពឹងអ្នកតូចតាមការទាប ការគួរធ្វើបាននោះឯង ដូចស្តេចមហិស្សរាធិបតី បើមិនទទួលមេត្រីនឹងស្តេចស្រមោចនោះហើយ ដល់ក្លីសវាចូលត្រចៀក ធ្វើម្តេចនឹងយកក្លីសនោះចេញពីក្នុងត្រចៀកបាន ទៅប្រើស្តេចគ្រុឌ នាគ យក្ខ គន្ធព្វ កុម្ភណ្ឌ រាជសីហ៍នោះឯណា នឹងចូលក្នុងត្រចៀកបានៗ បទនេះអ្នកប្រាជ្ញគួរពិចារណាមើលជាគតិលោកហោងៗ

## ចប់តម្រាពឹងតូចរួចទុក្ខភ័យទី ១៣

មានសត្វស្មាន់១ ក្អែក១ អណ្តើក១ យកគ្នាជាសម្លាញ់តែងពឹងពាក់គ្នាទៅវិញទៅមកៗ ថ្ងៃ១ ស្មាន់ទៅរកស៊ីនៅព្រៃ១ ក៏ជាប់អន្ទាក់ព្រានព្រៃ ក្អែកនឹងអណ្តើកនាំគ្នាដើររកស្មាន់នោះលុះទៅដល់ជាយព្រៃក៏ស្រាប់តែឃើញស្មាន់ជាប់អន្ទាក់ ទើបចូលទៅសួរថា "សម្លាញ់ឯង ហេតុអ្វីដើររកស៊ីមិនមើលអន្តរាយ មកឲ្យជាប់បន្ទាក់គេយ៉ាងនេះ"ៗ ស្មាន់ក៏ឆ្លើយថា "ឱសម្លាញ់អើយ អញនេះបានជាខុសហើយចូរសម្លាញ់គិតកែខៃជួយអាយុអញផងចុះ"ៗ



ឯក្អែកនឹងអណ្តើកក៏ទទួលជួយដោះទុក្ខភៀនក្អែកហើរទៅពាំនាំទឹក មកស្រោចខ្សែអន្ទាក់ឲ្យទន់ឯអណ្តើកក៏ខាំខ្សែអន្ទាក់នោះឯង ក្អែកនឹងអណ្តើកព្យាយាមខាំកាត់អន្ទាក់នោះតាំងតែពីបឋមយាម ដរាបដល់បច្ឆិមយាម ទៀបនឹងភ្លឺស្វាងកាត់ដាច់បានពីរផ្លុងនៅសល់មួយផ្លុង ក៏ជួនពេលព្រានព្រៃមក ទើបក្អែកនឹងអណ្តើកតឿនសតិស្មាន់ថា "សម្លាញ់អើយពេលនេះម្ចាស់អន្ទាក់មកជិតដល់ហើយ យើងជួយកាត់បានតែពីរផ្លុងនៅសល់មួយផ្លុងចូរសម្លាញ់ខំបោលកន្ត្រាក់ដោយខ្លួនឯងឲ្យដាច់ចុះ"ៗ កាលសត្វទាំង៣ កំពុងនិយាយគ្នាដូច្នោះ នាយព្រានព្រៃក៏មកដល់ ទើបក្អែកនឹងអណ្តើកក៏ចេញចាកទីនោះចូលទៅពួនក្នុងព្រៃនៅខាង ចាំមើលដំណើរស្មាន់នោះឯង ឯស្មាន់សោតកាលបើនាយព្រានមកដល់ខ្លួនក៏ស្ទុះកន្ត្រាក់ផ្តាច់អន្ទាក់នោះដាច់បានហើយបោលចូលព្រៃទៅហោងៗ

ឯនាយព្រាននឹកស្តាយស្មាន់ណាស់ ក៏រត់ដេញស្មាន់នោះតែតាមពុំទាន់ ទៅប្រទះលើអណ្តើកដែលពួននោះ ទើបនាយព្រានចាប់អណ្តើកនោះហើយក៏វិលមកធ្វើអន្ទាក់នោះទៀតៗ

ឯក្អែកឃើញនាយព្រានចាប់អណ្តើកបានដូច្នោះក៏និយាយនឹង

ស្នាន់ថា ចូរអ្នកក្លែងធ្វើជាបាក់ជើងដើរទៅខាងមុខនាយព្រាន ដេញ នាយព្រានគង់នឹងដាក់អណ្ដើកចោលនៅកណ្ដាលវាលរត់ ដេញអ្នកឯងមិនលែង ហើយអ្នកឯងនឹងរត់គេចមកក្រោយវិញ ខាំពាំអណ្ដើកនោះបោលចូលព្រៃទៅ ឲ្យរួចពីដៃអាព្រានព្រៃ នោះ ។

ឯស្នាន់ក៏ធ្វើតាមពាក្យក្អែកបង្គាប់នោះឯង លុះស្នាន់បោលទៅ ជិតនាយព្រានហើយ ក៏ធ្វើអាការជាសត្វបាក់ជើងម្ខាង បោល បោះតែជើង៣ ចំពោះមុខព្រានព្រៃនោះឯង ឯនាយព្រានពុំ ដឹងអាការសត្វក៏សំគាល់ថា ស្នាន់នេះ ត្រូវអន្ទាក់វាខំកន្ត្រាក់ទាល់ តែដាច់បាន ទំនងជាវាបាក់ជើងនេះ ព្រោះខ្សែអន្ទាក់អញវា វាត់ត្រូវនោះឯង គិតហើយនាយព្រាន ក៏ដេញទៅដើម្បីនឹង ប្រហារ ។

ឯស្នាន់បែរមក ឃើញនាយព្រានមិនទាន់ដាក់អណ្ដើកចោល ដូច្នោះក៏ក្លែងធ្វើជាពុំលឿង បោលទៅបន្តិចៗ នាយព្រានចូល ចិត្តថាស្នាន់ពិការជើងបោលពុំលឿនដូច្នោះ ក៏គិតថា អញ ប្រយោជន៍អ្វីនឹងអាអណ្ដើក១ សាច់វាល្មស៊ីបានតែព្រឹកល្ងាច ប៉ុណ្ណោះគួរតែចោលវាចេញចុះ នឹងខំដេញចាប់អាស្នាន់ឲ្យបាន



ដ្បិតវាជាសត្វធំសាច់ច្រើន លើសអាអណ្ដើកនេះគិតហើយនាយ ព្រានក៏ចោលអណ្ដើកនោះនៅលើគុម្ពស្បូវ ហើយរត់តាមស្នាន់ នោះទៅ ៗ ឯស្នាន់ដឹងថានាយព្រានចោលអណ្ដើកហើយ ក៏រឹង ធ្វើកលបោលជន្លនាយព្រាន ឲ្យដេញចេញទៅផុតព្រៃស្បូវ បានឱកាសហើយ ស្នាន់ក៏បោលគេចមកក្រោយបានទៅដល់ អណ្ដើកហើយ ក៏ពាំអណ្ដើកនោះបោលបោះផ្លោះចូលទៅក្នុង ព្រៃធំ ៗ ឯក្អែកក៏ហើរនាំផ្លូវទៅដរាបដល់ព្រៃ១ ជាព្រៃផុត មនុស្សដើរទៅដល់សត្វទាំង៣ ក៏នាំគ្នាអាស្រ័យនៅក្នុងព្រៃ នោះជាសុខសប្បាយហោ ៗ

រឿងនិទាននេះ ឯងយល់ចុះក្នុងគតិយ៉ាងណាចូរថាទៅមើល ៗ

កូនសិស្សក៏តបថា រឿងនេះចុះគតិកល្យាណមិត្រល្អបុគ្គល ឯណាបានមិត្រល្អ យ៉ាងក្អែកនឹងអណ្ដើកដែលជួយដោះស្នាន់ជា មិត្រឲ្យរួចចាកទុក្ខបានបុគ្គលនោះហៅថាមានមិត្រល្អ គួរគប្បី សេគប់ ក៏ឯមិត្រនេះលោកសំដែងថា កុលបុត្រគប្បីបំរុង ដោយស្ថាន៥ ប្រការ គឺបែងចែកវត្ថុឲ្យ១ និយាយចរចាពាក្យ ពីរោះ១ ប្រព្រឹត្តប្រយោជន៍១ ភាវរជាអ្នកមានធុរៈឬខ្លួនស្មើ ជាប្រក្រតី១ មិនក្លែងពោលពាក្យឲ្យឃ្លៀងឃ្លាតចាកក្ដីពិត១ ៗ

មិត្របានទទួលបំរុងដូច្នេះហើយត្រូវអនុគ្រោះកុលបុត្រនោះ ដោយស្ថាន៥ ប្រការវិញ គឺឃើញមិត្រនោះ ដល់នូវក្ដីលំបាកនាទីស្ថានឯណាមួយ ហើយស៊ូនៅរក្សាមិត្រ ពុំគិតលះចោលយ៉ាងនេះប្រការ១ ជួយរក្សាទ្រព្យសម្បត្តិរបស់មិត្រ ដែលមិត្រលុះក្ដីប្រមាទ១ កាលបើមានភ័យ ទទួលជាទីពឹងពុំនាក់បាន១ មិនលះចោលមិត្រក្នុងកាលវិបត្តិ មានកាលស្រូវថ្លៃជាដើម១ រាប់អានរហូតដល់វង្សញាតិរបស់មិត្រ១ ត្រូវជាស្ថាន៥ ប្រការហោងៗ បុគ្គលក្នុងលោក គប្បីរកមិត្រមានធម៌អនុគ្រោះ៥ ប្រការដូចសំដែងមកនេះ ទើបបានក្ដីសួស្ដីមង្គល ចំរើនក្ដីសុខសម្រាន្តដូចសត្វទាំង៣ នោះហោងៗ

## ចប់តម្រាគតិសុភមិត្រ។

មានសត្វស្នាន់១ ក្អែក១ ជាសម្លាញ់គ្នានៅយូរមក មានចចក១ដើរទៅជួបនឹងស្នាន់ ចូលទៅនិយាយមេត្រីក្ដីស្នេហានឹងស្នាន់នោះ ស្នាន់សោតក៏លុះក្ដីស្រឡាញ់ចចកយ៉ាងស្និទ្ធ សត្វទាំងពីរតែងទៅមករកគ្នាជាញឹកញយ ៗ

ឯក្អែកជាសត្វមានប្រាជ្ញា ស្គាល់អាការកិរិយានៃចចកនោះជាសត្វកោងឥតក្ដីសុចរិត ទើបនិយាយហាមស្នាន់ថា "អ្នកឯងកុំទៅចូលចិត្តស្រឡាញ់អាចចកនោះឡើយ អាចចកនោះមិនស្លូតត្រង់តមិត្រឯងទេ វាជាសត្វប្រចុបប្រចែង ក្លែងធ្វើជាមិត្រស្និទ្ធស្នាលនឹងអ្នកឯង ធ្វើឲ្យអ្នកលុះលង់ដោយកលវាៗ នឹងយាយីអ្នកឯងវិញពុំខាន"ៗ ឯស្នាន់នោះលុះអំណាចកលចចកមកយូរហើយ លុះឮក្អែកជាមិត្រពោលហាមក៏ពុំតាមពាក្យក្អែកនោះឡើយ ឯចចកក៏បេះតែបបួលស្នាន់ទៅលេងនឹងទីខ្លួនរឿយៗ



ថ្ងៃមួយចចកបានឃើញអន្ទាក់ព្រានព្រៃតាំងនៅដោយព្រៃ១ ទើបកើតក្ដីទ្រុស្ដមិត្រគិតថាចាំអញទៅបបួលស្នាន់ ឲ្យវាមករកស៊ីនៅទីនេះនឹងបញ្ឆោតវា ឲ្យជាប់អន្ទាក់ព្រានព្រៃនេះដល់វាស្លាប់អញនឹងស៊ីវាហោងៗ ចចកគិតដូច្នោះ គឺទៅកាន់សំណាក់នៃស្នាន់ ដល់ហើយទើបនិយាយបបួលថា "សម្លាញ់អើយមកយើងនឹងទៅរកស៊ីនៅទីជាយព្រៃខាងនោះ ព្រៃនោះខ្ញុំធ្លាប់ទៅរកអាហារបរិភោគងាយណាស់ ឯខាងស្មៅឬស្លឹកឈើជាចំណីមិត្រឯងសោត ក៏មានបរិបូណ៌តាមចិត្តនឹងបរិភោគ"ៗ

ឯស្នាន់បានឮចចកបបួលដូច្នោះ ក៏ទៅតាមចចកៗ ក៏នាំស្នាន់ទៅត្រង់ទីអន្ទាក់ព្រានព្រៃនោះឯង ស្នាន់សោត ឆោតមិនដឹងកលមិត្រ គិតនឹងប្រទូស្តអាត្មាដើរទៅៗ ជាន់ទៅលើអន្ទាក់ៗ

ក៏វាតិព័ទ្ធជើងក្រោយនៃស្ទាន់យួរឡើង ស្ទាន់ក៏ភិតភ័យតក្កមាស្រែកឲ្យចចកជួយ ចចកក៏ធ្វើកិរិយាដូចជាភ្ញាក់ផ្អើលនឹងមនុស្សមកដល់ខ្លួន ស្ទុះរត់ទៅពួននៅក្នុងព្រៃស៊ុមទ្រុមសម្ងំចាំមើលស្ទាន់នោះ នឹងបម្រះនៀលកន្ត្រាងទៅយ៉ាងណា បើស្ទាន់អស់កម្លាំងដួលចុះកាលណា នឹងចេញមកស៊ីស្ទាន់នោះឯង ។

ថ្លែងពីក្អែក កាលបើពុំឃើញស្ទាន់នៅទីប្រក្រតីក៏ហើររកស្ទាន់នោះ តាមដងព្រឹក្សព្រៃដរាបទៅដល់ទីជាយព្រៃ ក៏បានឃើញស្ទាន់ជាប់អន្ទាក់ព្រានព្រៃទើបហើរចុះទៅទំលើមែឈើ ហើយនិយាយទៅថា "ៈទំហសម្លាញ់អើយ! ហេតុអ្វីក៏បានជាមកប្រមាទការឲ្យជាប់អន្ទាក់មនុស្សយ៉ាងនេះ" ។

ស្ទាន់តបថា "ការអស់នេះគឺខ្លួនខ្ញុំឯងខុសពិតហើយ ព្រោះអាចចកវាបញ្ឆោតឲ្យមករកស៊ីនៅទីនេះវានាំឲ្យឯងជាប់អន្ទាក់គេ ត្រង់ខ្លួនវាគេចរត់បាត់ពីទីនេះទៅ មិនដឹងជាវាទៅឯណា អើសំឡាញ់ចូរអាណិតដោះខ្ញុំឲ្យរួចពីអន្ទាក់នេះម្តងចុះ" ។

ឯក្អែកក៏ប្រាប់ឧបាយស្ទាន់ថា "បើនាយព្រាណមកដល់កាលណា ចូលអ្នកឯងក្លែងធ្វើជាស្លាប់ តាំងរូបឲ្យរឹងប្រឹងអត់ដង្ហើមធ្វើឲ្យនាយព្រានទុកចិត្តថាស្លាប់មែន បើនាយព្រានដោះអ្នក



ឯងកាលណា អ្នកចាំពាក្យខ្ញុំថាខ្វក បើឮពាក្យខ្ញុំថាខ្វកកាលណា ចូរអ្នកឯងខំស្ទុះបោលបោះផ្លោះរត់ចូលព្រៃទៅ ឲ្យផុតអំពីដៃមនុស្សហោង" ឯស្ទាន់ក៏ទទួលពាក្យបង្គាប់នៃក្អែកសព្វគ្រប់ប្រការ ។

លុះដល់ពេលនាយព្រានព្រៃរៀបខ្លួនហើយយាត្រាទៅមើលអន្ទាក់ ស្រាប់តែឃើញស្ទាន់ដេកស្លាប់ក៏ចូលចិត្តថាស្ទាន់ដេកស្លាប់យូរហើយ ទើបប្រមាទដោះស្ទាន់ចាកអន្ទាក់ដាក់ម្ខាង ហើយឈរឡើងមើលឆ្វេងមើលស្តាំ ។ ឯក្អែកឃើញនាយព្រានប្រមាទហើយ ក៏ស្រែកខ្វកជាសញ្ញាឡើងមួយរំពេច ស្ទាន់ក៏ស្ទុះឡើងបោលបោះ ផ្លោះរត់ចូលព្រៃទៅជាមួយនឹងក្អែកជាអ្នកនាំផ្លូវ ឯនាយព្រានព្រៃឃើញស្ទាន់រស់បោលផ្លោះដូច្នោះក៏ស្ទុះចាប់លំពែងរត់ដេញដល់ទីមួយក៏ពួយលំពែងទៅត្រង់ព្រៃស៊ុមទ្រុម លំពែងនោះក៏ធ្លាក់ទៅត្រូវគល់កនៃចចក ដល់នូវក្តីមរណកាលក្នុងព្រៃស៊ុមទ្រុមនោះឯង ។

ឯក្អែកក៏ហើរនាំស្ទាន់ទៅកាន់លំនៅ ផុតអន្តរាយនឹងព្រានយាយីហោង ។

រឿងនិទាននេះ បានគតិយ៉ាងណាឲ្យថាទៅមើល? ។

កូនសិស្សតបថា ចចកទ្រុស្តមិត្របង់ជីវិតខ្លួនឯងបានគតិធម៌ថា បុគ្គលសុចរិតក្តីប្រទូសរាយតបមនុស្សឯណាមួយហើយៗ មនុស្សនោះទៅប្រទូសរាយតគេឥតទោសនឹងខ្លួន យ៉ាងដូចសត្វចចកទៅប្រទូសរាយតស្មាន់ជាមិត្រឥតទោស យ៉ាងនេះលោកថាក្តីទុក្ខទោសវិបត្តិអពមង្គល នឹងធ្លាក់ដល់មនុស្សនោះឯង ដូចចចកត្រូវលំពែងព្រានព្រៃនោះហោងៗ

**ចប់តម្រាផនទ្រុស្តមិត្រទី ១៥។**

មានស្តេចព្រាប១ នាំបរិវារទៅរកស៊ីនៅទីវាលស្រែបានឃើញលប់ ដែលនាយព្រានដាក់ហើយបាចសាចស្រូវអង្ករជានុយ ពួកព្រាបជាបរិវារទាំងឡាយឃើញនុយដូច្នោះ គិតនាំគ្នានឹងចុះស៊ីៗ

ឯស្តេចព្រាបគិតថាស្រូវអង្ករនេះ ជារបស់រកបានដោយក្រចុះហេតុម្តេច ក៏មនុស្សយកមកបាចសាចចោលរាយពាសដូច្នោះ ទំនងជានុយបញ្ឆោតឲ្យពួកព្រាបចុះស៊ី ហើយគេនឹងវាត់ចាប់ដោយលប់នេះឯងជាប្រាកដ ស្តេចព្រាបគិតដូច្នោះហើយ ទើបពោលហាមព្រាបជាបរិវារ មិនឲ្យចុះស៊ីស្រូវនោះឡើយៗ



ឯព្រាបជាបរិវារទាំងឡាយពុំស្តាប់ទើបនិយាយគ្នាថា "យើងស្វែងរកអាហារសព្វថ្ងៃនេះ បានដោយកម្រ ឥឡូវនេះមកបានឃើញអាហារល្មមបរិភោគហើយៗ នាយយើងហាមឃាត់មិនឲ្យចុះស៊ីយ៉ាងនេះតើនឹងចាំទៅរកឯណាទៀតឲ្យលំបាក"ៗ

ស្តេចព្រាបឮដូច្នោះក៏ថា "អ្នកទាំងឡាយគ្មានប្រាជ្ញា ឃើញតែអាហារក៏ហើរចុះស៊ី ពុំនឹងគិតអន្តរាយទៅខាងមុខ នឹងបានទុក្ខដល់អាត្មាដូចពាក្យបុរាណថា "ព្រោះចំណីត្រូវក្តីច្រើនក្តាត់" នៃអ្នកទាំងឡាយស្រូវអង្ករ ដែលគេរាយពាសវាលនេះគឺជានុយដូចជាត្រីស៊ីនុយ ជាប់សន្ទូចគេនោះឯងហើយ ចូរអ្នកទាំងឡាយកុំចុះទៅស៊ីស្រូវគេនោះឡើយ"ៗ

ឯព្រាបទាំងឡាយពុំជឿស្តាប់ស្តេចព្រាបហាមឡើយ នាំគ្នាចុះទៅស៊ីស្រូវ ក្នុងលប់នាយព្រានឯស្តេចព្រាបឃាត់បរិវារពុំស្តាប់ដូច្នោះ ក៏គិតថា "បើអញមិនចុះទៅផងមុខជាព្រាបអស់នេះនឹងវិនាសដោយដៃមនុស្សពុំខាន ល្ហើយចុះអាត្មាត្រូវចុះទៅជាមួយផងចុះ" គិតហើយស្តេចព្រាបក៏ហើរចុះទៅក្នុងលប់នោះឯងៗ

ឯនាយព្រានឃើញព្រាបចុះច្រើនហើយ ក៏ទំលាក់ខ្សែលប់

នោះចុះមួយរំពេចព្រាបទាំងឡាយក៏ត្រូវដូចគេទេវចក្នុងសំណាញ់នោះជាម្តង ទើបស្តេចព្រាបនិយាយថា "ម៉េចអ្នកទាំងឡាយឃើញក្តីអន្តរាយជីវិតពិតហើយឬ បើដូច្នេះអ្នករាល់គ្នានឹងគិតយ៉ាងណាទើបរក្សាជីវិតបាន? ។

ឯព្រាបទាំងឡាយ នាំគ្នាទទួលទោសខុសហើយថា "យើងខ្ញុំទាំងឡាយពុំដឹងគិតយ៉ាងណាទេ ទាល់ចំណេះអស់ហើយ លោកមានឧបាយយ៉ាងណាសូមមេត្តាដោះទុក្ខយើងខ្ញុំឲ្យរួចជីវិតផង" ។

ឯស្តេចព្រាបថា "ភ័យម្តងនេះជាភ័យយ៉ាងធំបំផុតកម្រនឹងកែខ្លួនបាន បើដូច្នោះអ្នករាល់គ្នាកុំប្រមាទខំឧស្សាហ៍តាំងសតិឲ្យខ្ជាប់ចុះ អាស្រ័យការព្រមព្រៀងចិត្តគ្នា ខំតាំងកំលាំងឲ្យព្រមគ្នាចុះ យើងប្រឹងស្ទុះហើរឡើងឲ្យព្រមគ្នា ដើម្បីនឹងឲ្យលប់នេះដាច់ឃ្លាតចាកទី" ។

ឯព្រាបទាំងឡាយក៏ធ្វើតាម ទើបនាំគ្នាស្ទុះហើរព្រមគ្នា ឯខ្សែលប់ក៏ដាច់ចាកទី១ រំពេចព្រាបទាំងឡាយ ក៏ហើរនាំលប់នោះឡើងទៅលើអាកាសបាន ហើយហើរទៅដល់ដំបូកមួយជាលំនៅនៃស្តេចកណ្តុរដែលជាសំឡាញ់ នឹងស្តេចព្រាបអំពីដើមមក ។ ថ្ងៃដែលព្រាបទាំងឡាយទៅធ្លាក់លើដំបូកនោះ ស្តេច



កណ្តុរបានដឹងថាស្តេចព្រាបព្រមទាំងបរិវារជាប់លប់ហើរមកធ្លាក់ដូច្នោះ ក៏នាំបរិពារនៃអាត្មាចេញពីដំបូកមកកាត់លប់នោះដាច់ដាច នាំយកព្រាបទាំងនោះចេញអំពីលប់នោះបាន ឯស្តេចព្រាបព្រមទាំងបរិវារ ក៏បានរួចចេញចាកលប់ហើយប្រារព្វប្រស្រ័យចរចាប្រាប់សេចក្តីសុខទុក្ខគ្នា ទាំងពីរដើមដល់ចប់គ្រប់ប្រការ ស្តេចព្រាបក៏សរសើរគុណនៃស្តេចកណ្តុរជាកល្យាណមិត្រផ្សេងៗហើយក៏លាគ្នាទៅកាន់លំនៅទីទៃៗហោង ។

រឿងនិទាននេះ បានគតិយ៉ាងណាចូរសំដែងទៅមើល? ។

កូនសិស្សតបថា រឿងស្តេចព្រាបនោះបានគតិគឺនាយល្អនាយប្រពៃ បុគ្គលអ្នកស្វែងរកនាយចៅហ្វាយឲ្យបានក្តីសុខនោះគប្បីស្វែងរកនាយចៅហ្វាយដែលប្រកបដោយសតិបញ្ញាអាចជួយដោះបាវឲ្យរួចចាកក្តីទុក្ខទោសបាន ដូចយ៉ាងស្តេចព្រាបដែលឃាត់ពួកបរិវារពុំបាន ហើយដឹងថាអន្តរាយចំពោះជានឹងមានដល់ពួកព្រាបជាបរិវារប្រាកដហើយ ពុំគិតលះបង់ចោលបរិវារឡើយ ស៊ូរប្រថុយអាត្មាចូលក្នុងលប់នាយព្រានជាមួយគ្នា ហើយដាស់តឿនបរិវារឲ្យប្រឹងស្ទុះហើរផ្តាច់លប់

ដោយព្រមព្រៀងចិត្តគ្នា បានរួចផុតក្តីភ័យអន្តរាយនោះបានៗ

មួយទៀតឯលប់រូបសំណាញ់គឺមនុស្សធ្វើដោយខ្សែជាទម្ងន់ សត្វព្រាបអត្តភាពតូចកំលាំងតិចអាចផ្តាច់នាំហើរយកទៅបាន ទាំងនេះក៏ព្រោះក្តីសាមគ្គីព្រមចិត្តគ្នា តាំងព្យាយាមដោយកំលាំងស្មើគ្នាវត្ថុធំពិត តែបើកំលាំងឬព្យាយាមស្មើគ្នាហើយ វត្ថុធំនោះអាចនាំទៅបាន គតិនេះដូចបទបាលីមានក្នុងគម្ពីរលោកនីតិថា

**ពហូនំ អប្បសារានំ**

**សាមគ្គិយា ជយាជយេ**

**តិណេន យោត្តំ វត្តកោ**

**តេន នាគោបិ ពន្ធតិ។**

ជនប្រាសចាកគុណគប់គ្នាច្រើន តែចំរើនដោយក្តីសាមគ្គី អាចផ្ចាញ់បាននូវពួកខែនខែពរី ដោយរិទ្ធិសាមគ្គីដ៏ហាវហានៗ ខ្សែព្ទួរគឺជនទេវញ្ញដោយស្មៅនាំយកទៅចងព័ន្ធដំរីបាន រូបតូចពិតតែចិត្តស្មោះស្មើប្រាណ គង់ផ្ចាញ់បានរូបធំវលំអឺយ ៗ

មួយទៀតបុគ្គលអ្នកស្វែងរកនាយចៅហ្វាយល្អនោះត្រូវរើសនាយល្អប្រកបដោយសង្គហធម៌៥ ប្រការគឺចាត់ការងារឲ្យបាវធ្វើតាមសមគួរដល់កំលាំង១ ឲ្យអាហារនិងរង្វាន់ដល់បាវ



១ ជួយរក្សាព្យាបាលក្នុងវេលាបាវឈឺចាប់១ បែងចែករបស់មានរសប្លែកឲ្យបាវបានបរិភោគផង១ លើកលែងការងារក្នុងសម័យកាល គឺបើកបាវឲ្យទៅធ្វើបុណ្យទានតាមចិត្ត១ៗ

នាយប្រកបដោយសង្គហធម៌៥ ប្រការនេះទើបហៅថានាយល្អនាយប្រពៃ គប្បីបាវចូលសេពគប់ៗ មួយទៀតក្នុងគម្ពីរលោកនីតិសំដែងថា៖

**ន សេវ ផរុសី សាមី ន ច សេវេយ្យ មច្ឆរី**

**តតោអបត្តណ្ហំសាមី នេវ និត្តហិតំតេតោ**

នាយអាក្រក់មិនគួរសេពគប់នោះមានអធិប្បាយថា កុំសេពម្ចាស់គ្រោតគ្រាតជាតិប្រវ័ញ្ចន៍ កុំសេព ម្ចាស់កំណាញ់គិតកាញ់ទុន កុំសេពម្ចាស់មិនលើកដំកល់គុណ កុំសេពម្ចាស់យកបុណ្យមកសង្កត់ៗ

មួយទៀតលោកខែសេចក្តីថា ម្ចាស់កំណាញ់ពេញកំណាចលើសម្ចាស់គ្រោត ម្ចាស់ថយជាតិមិនលើកលើសកំណាញ់ ម្ចាស់ផ្ចេញផ្ចាល់ជួសលើសមិនលើកវិញ ម្ចាស់៤ នេះកុំស្រឡាញ់យកជាម្ចាស់ៗ

**ចប់តម្រាគតិនាយល្អទី ១៦។**

មានសត្វចចកទាំងឡាយក៏ច្រើនអាស្រ័យនៅលើកោះ១ កណ្តាលសាគរថ្ងៃមួយនិយាយប្រឹក្សាគ្នាថា យើងជាសត្វអាស្រ័យសាច់សត្វជាភក្សាហារតែស្វែងរកអាហារបានដោយក្រ ទោះជាបានខ្លះសោតក៏ពុំបរិបូណ៌ ហេតុដូច្នេះគ្នាយើងគួរតែទៅនិយាយលបួងបញ្ឆោតដំរីសារធំ ឲ្យវាចុះកលយើងៗ នឹងបានសាច់វាបរិភោគបរិបូណ៌ ហ្វូងចចកគិតឃើញឧបាយដូច្នេះហើយ ទើបនាំគ្នាហែលទឹកទៅកាន់ត្រើយស្ទឹងចូលទៅកាន់សំណាក់នៃដំរីសារ ដល់ហើយក៏ធ្វើកិរិយាជាអ្នកកោតខ្លាច ឱនសិរសាចុះគំនាប់គោរពដំរីហើយស្រដីថា "បពិត្រលោកជាធំដ៏ប្រសើរសូមលោកមេត្តាប្រោសដល់ពួកយើងខ្ញុំ ដ្បិតយើងខ្ញុំទាំងឡាយសព្វថ្ងៃនេះ ឥតមាននាយចៅហ្វាយនឹងជួយការពារក្តីអន្តរាយសោះ ឥឡូវបានប្រឹក្សាគ្នាឃើញថា ព្រះតេជព្រះគុណនេះ ជាសត្វធំឧត្តមសមគួរជានាយលើយើងខ្ញុំទាំងឡាយៗ ប្រគល់កាយជាបាទបំរើព្រះតេជព្រះគុណចាប់ដើមពីថ្ងៃនេះតទៅ"។

ឯដំរីសារឥតប្រាជ្ញា បានឮចចកទាំងឡាយនោះមកនិយាយបញ្ឆោតដូច្នោះ ក៏ត្រេអរស្រុះស្រួលទទួលជានាយលើហ្វូងចចក។



ឯចចកទាំងឡាយចាប់ដើមពីថ្ងៃនោះមកវានាំគ្នាគោរពប្រតិបត្តិបំរើដំរីដោយក្តីមាយា ថ្ងៃមួយចចកនាំគ្នាចូលទៅវន្ទាដំរីស្រដីបបួលថា "បពិត្រលោកជានាយ ហើយខ្ញុំទាំងឡាយអាស្រ័យនៅក្នុងទីព្រៃនេះពុំសប្បាយ ព្រោះរកអាហារបានដោយក្រ សូមទានយើងខ្ញុំ សូមអញ្ជើញលោកនាយឆ្លងទៅនៅឯកោះធំ កោះនោះបរិបូណ៌យើងខ្ញុំនឹងហែហមឡោមលោកនាយទៅនៅឯកោះនោះ នឹងបានជាអធិបតីលើពួកយើងខ្ញុំទាំងឡាយ មួយទៀតឯពួកយើងខ្ញុំដែលនៅឯកោះនោះ ក៏មានច្រើនគ្នា សូមលោកនាយមេត្តាត្រាទៅជាកំពូលនៃយើងខ្ញុំហោង"។

ឯចចកនៅកោះបានឮពួកខ្លួនខាងត្រើយលូឡើងដូច្នោះក៏នាំគ្នាលូកងឡើងទទួលគ្នា ហើយប្រុងប្រៀបអាត្មាទីទៃៗ ដើម្បីនឹងចុះហែលទឹកទៅជួយគ្នាខាំដំរីនោះ ឲ្យលុះក្ដីមរណកាលកណ្ដាលមហានទីនោះឯង។

ឯដំរីសារស្រាវឹងបុណ្យហែលមកដល់កណ្តាលមហាទី ត្រូវទឹកជ្រៅផុតជើងផុតដៃ នឹងអាស្រ័យផ្ទៃផែនដីពុំបាន ក៏អណ្តែតខ្លួនប៉ើងប៉ោងៗ ឯចចកទាំងឡាយដឹងជាដំរីផុតជើងផុតដៃ

នឹងអាស្រ័យព្រៃចាក់ពុំបានដូច្នោះ វាក៏នាំគ្នាហែលឡើងទំលើខ្នងហើយខាំកកេរសាច់ពោះដំរីត្រាតែធ្លុះ ទឹកក៏ចូលទៅក្នុងពោះដំរីនោះពេញ ដំរីនោះដល់នូវក្តីមរណកាលកណ្តាលគង្គា ពួកចចកក៏នាំគ្នាបរិភោគសាច់ដំរីតាមសេចក្តីប្រាថ្នាវាហោង ៗ

រឿងនេះ បានគតិអ្នកតូចព្រមព្រៀងអាចផ្ចាញ់អ្នកធំបាន ដូចគ្នានឹងបទបាលីក្នុងគម្ពីរលោកនីតិដែលថា ពហូនំ អប្បសារានំ ៗល ៗ ដែលបានអធិប្បាយមកហើយ ៗ

មួយទៀត ដំរីនោះបានគតិឆ្កួតយសឡើងបញ្ជោរដូចគតិក្អែកឡើងបញ្ជោរសំពោច ខូចធំទឹកដោះនោះឯង គួរចូលចិត្តចុះ ៗ

ចប់តម្រាគតិព្រមព្រៀងទី ១៧។ល។

មានសត្វកណ្តុរទាំងឡាយដ៏ច្រើន អាស្រ័យនៅក្នុងទីមួយ បានសេចក្តីក្តៅក្រហាយលំបាកដោយមេឆ្មា១ តែងយាយីនឹងចេញរកស៊ីពុំបាន ថ្ងៃមួយកណ្តុរទាំងឡាយមកប្រជុំជំនុំគ្នាថា "ពួកយើងមានគ្នាច្រើន មេសត្រូវគឺមេឆ្មា១ គួរតែយើងស្រុះគ្នាចូលយុទ្ធនានឹងវាជាសត្រូវ ចោមគ្នាខាំសម្លាប់មេឆ្មានោះបង់ចេញទើបពួកយើងបានក្តីសុខសប្បាយតទៅ" ៗ



ឯកណ្តុរទាំងឡាយ សឹងខ្លាចអំណាចមេឆ្មានោះមហិមា លុះឮពាក្យជំនុំដូច្នោះ ក៏ពុំអាចនឹងទទួលសឹងនាំគ្នាពោលឡើងថា "យើងរាល់គ្នាសឹងពុំហ៊ានចូលតយុទ្ធនឹងឆ្មានោះទេ" ៗ

គ្រាកាលនោះ មានកណ្តុរ១ឆ្លើយឡើងថា "ខ្ញុំមានឧបាយមួយល្អមនឹងរក្សាជីវិតបាន ឯឧបាយនោះ គឺថាយើងទៅរកចង្រ្កង់បាន១ យកមកចងកឆ្មា ថាបើវាទៅឯណាៗ យើងស្តាប់ចង្រ្កង់វាជាសញ្ញាគឺថាបើឮសូរចង្រ្កង់ទិសខាងកើត យើងដឹងថាមេឆ្មានៅខាងកើត ហើយយើងនាំគ្នាចេញរកស៊ីទិសខាងលិច បើឮខាងលិចសឹមយើងគេចទៅរកស៊ីខាងកើតវិញ ឧបាយយ៉ាងនេះ តើអ្នកទាំងឡាយយល់ថាត្រូវខ្លះឬទេ" ៗ

ឯកណ្តុរទាំងឡាយ ក៏ឆ្លើយឡើងព្រមគ្នាថា "ឧបាយដែលអ្នកគិតនេះយល់ត្រូវហើយ តែថាបើរកចង្រ្កង់បានមក តើរូបអ្នកណាអាចក្លាហាមយកចង្រ្កង់ទៅចងកឆ្មានោះបាន" ៗ

ឯកណ្តុរទាំងឡាយជំនុំដូច្នោះ សឹងខ្លាចពុំហ៊ានទៅចងកឆ្មានោះទាំងអស់គ្នា សេចក្តីជំនុំនោះក៏មិនសំរេចទៅបាន ជាអសាឥតការទេហោង ៗ រឿងនេះបានគតិដូចរូបអ្នកតូចទាំងឡាយច្រើនគ្នា កើតខាត់ដោយអ្នកធំមានអំណាច មិនអាចទៅ

ធ្វើអ្វីគេបានក្តៅក្រហាយណាស់ ជំនុំតែគ្នាឯងដូចហ្វូងកណ្តុរជំនុំគ្នានឹងយកចង្រ្កង់ទៅចងកឆ្មានោះឯង ។ អ្នកមានបញ្ញាគួរពិចារណាមើលហោង ។

### ចប់តម្រាគិតមិនស្រុះគ្នា ទី ១៨។

មានបុរសពីរនាក់ ម្នាក់មានប្រពន្ធជាស្ត្រីកាឡកិណីម្នាក់ទៀតមានប្រពន្ធជាស្ត្រីប្រកបដោយលក្ខណា ។ ជនទាំងពីរត្រកូលនោះ យកគ្នាជាមិត្រសម្លាញ់ តែងទៅមករកគ្នាជានិច្ច ។ ថ្ងៃមួយចៅបុរសប្រពន្ធមានល័ក្ខណ៍ ទៅបានគងមង្គលអំពីសំណាក់ទេវតាៗ ឲ្យយកមកវាយ យកមាសប្រាក់ កែវកង សំពត់អាវគ្រឿងឧបភោគបរិភោគសព្វប្រការ ឯចៅមាណពប្រពន្ធខាតល័ក្ខណ៍ បានដឹងថា សម្លាញ់អាត្មាកើតមានទ្រព្យសម្បត្តិដោយអំណាចគងមង្គលហើយ ទើបទៅកាន់ផ្ទះសំឡាញ់ ហើយសុំខ្ចីគងមង្គលនោះ ទៅវាយ ដើម្បីកើតមានប្រាក់កែវកងដូចគេ ឯចៅបុរសក៏ព្រមឲ្យខ្ចី ហើយមាថាសំឡាញ់ឯង យកគងយើងទៅវាយនោះ គឺវាយបានតែក្នុងខណៈ ៣ ដងតែលើសអំពី ៣ដងទៅពុំបានទេ មួយទៀតចូរសំឡាញ់ឯង រៀបទៀន ធូប ភ្ញីផ្កា គ្រឿងពិធីឲ្យល្អប្រយ័ត្នមាត់ក កុំឲ្យពោល



ហួសប្រមាណ ចូរអធិដ្ឋានសំដៅយកវត្ថុមួយៗទើបសំរេច ។

ឯចៅមាណពនោះ ក៏ទទួលពាក្យសម្លាញ់គ្រប់ប្រការ ហើយកាន់យកគងនោះលាទៅផ្ទះអាត្មា មានសេចក្តីត្រេអរនឹងបានទ្រព្យសម្បត្តិក្រៃពេកណាស់លុះទៅដល់ ក៏និយាយប្រាប់ប្រពន្ធសព្វសេចក្តីហើយប្រើប្រពន្ធរៀបគ្រឿងបូជា ឯមេកាឡកិណីឮប្តីប្រើឲ្យរកទៀន ធូប លាជ ផ្កា ដូច្នោះ ក៏ពុំទទួលរកទាំងពុំមានចិត្តជឿគងមង្គលនោះផង ។

ឯចៅប្តីឃើញប្រពន្ធខ្លួនពុំអើពើផងដូច្នោះ ក៏ស៊ូស្វៀមនៅតាំងរកទៀនធូបដោយខ្លួនឯង បានហើយក៏តាំងបូជា លើកគងនោះ នឹងវាយយកមាសប្រាក់ ដល់ទំលាក់អន្លូងដល់ដោះគងនោះកាលណាមេកាឡកិណីវាស្រែកដង្ហោយឡើងថា "អង្គជាតិអើយចូរមកឲ្យច្រើនៗទៅ" និមិត្តតែផុតមាត់កាលណា វីអង្គជាតិទាំងឡាយក៏កើតឡើងជាប់តាមអវយវៈរាងកាយនៃចៅប្តីនោះៗ ក៏ភិតភ័យមហិមាស្រែកហៅឲ្យប្រពន្ធជួយ ។

ឯមេប្រពន្ធក៏ភិតភ័យ ទើបថា "ចូរអ្នកឯងវាយគងឡើងបណ្តេញឲ្យវាបាត់ទៅវិញ" ។ ចៅប្តីក៏ឧទ្ទិសថា "អង្គជាតិអើយចូរអន្តរធានបាត់ឲ្យអស់ទៅវិញទៅ" ថាហើយក៏វាយគងនោះ

ជាគំរពពីរដងឡើងនិមិត្តតែផុតពាក្យផុតសូរគងនោះកាលណា ឯអង្គជាតិទាំងនោះ ក៏អន្តរធានបាត់ទៅវិញ មិនបាត់តែអង្គជាតិថ្មីនោះឡើយ ទាំងអង្គជាតិចាស់គឺអង្គជាតិកំណើតខ្លួនក៏បាត់ទៅទាំងអស់ បុរសស្ទាបមើលដឹងថាអង្គជាតិកំណើត គឺពូជចាស់របស់ខ្លួនបាត់ទៅផងដូច្នោះក៏ប្រាប់ទៅប្រពន្ធថាគេហ៏អើយ ឥឡូវនេះពូជចាស់យើង ក៏វាបាត់ទៅជាមួយនឹងពូជថ្មីនេះហើយ"ៗ មេប្រពន្ធឮដូច្នោះក៏ភិតភ័យខ្លាំង ទើបប្រាប់ប្តីឲ្យវាយគងហៅអង្គជាតិកំណើត១ សម្រាប់ខ្លួនវិញៗ

ឯចៅនោះក៏លើកគងឡើងវាយ និយាយថា "គ្រឿងចាស់របស់ខ្ញុំអើយ! ចូរមកកើតដូចដើមវិញ" និមិត្តតែផុតពាក្យកាលណា អង្គជាតិចាស់ក៏កើតឡើងប្រាកដដូចដើមវិញហោងៗ

មេប្រពន្ធឃើញឥទ្ធិរិទ្ធិមង្គលនោះ ពូកែឆុតឆាប់ដូច្នោះក៏ថា "ចូរអ្នកស្វាមីវាយឡើងម្តងទៀតទៅខ្ញុំនឹងឧទ្ទិសហៅយកមាសប្រាក់ ឲ្យមានដូចគេវិញ"ៗ ចៅប្តីថា "វាយម្តងទៀតឯណាក៏បានគងនេះវាយបាន តែត្រឹមវារៈ៣ ដងឥឡូវឯងវាយអស់វារៈ៣ដងទៅហើយ គឺវាយក្នុងកាលបឋមនោះ ហងឯងទៅពាំនាំហៅយកអង្គជាតិ វាយទីពីរនឹងកែមាត់អង្គជាតិក៏បាត់ទៅទាំង



ចាស់ទាំងថ្មី វាយទីបីហៅបានតែគ្រឿងចាស់ដដែលមកវិញ នឹងវាយទី៤ ទៀតឯណាក៏បានត្រូវគេហាមផ្តាច់មកហើយ គិតទៅមេហងឯងជាកាឡកិណី ស្ត្រីអលក្ខិកា ធ្វើឲ្យខូចពិធីអញទៅហើយ" ថាហើយចៅនោះក៏យកគងមង្គលនោះទៅជូនម្ចាស់គេវិញហោងៗ

រឿងនិទាននេះ បានគតិដូចបុគ្គលគិតការមិនស្រុះគ្នា ការឯណាមួយតែធ្វើមិនព្រមព្រៀងគ្នា ហើយការនោះមិនសម្រេចទៅបានដូចនិទានមេកាឡកិណីនោះឯង អ្នកមានសតិបញ្ញាគួរពិចារណាទៅទៀតចុះៗ

### ចប់តម្រាកាឡកិណី នឹងមង្គលមិនស្រមគ្នាទី ១៩។

មានពពែពីរតួ ដើរមកទល់ជួបគ្នានៅកណ្តាលស្ពានពពែ១ ថាស្ពាននេះចំពោះដើរបានតែមួយៗ នឹងដើរចៀសគ្នាពុំបាន បើដូច្នោះត្រូវតែអ្នកឯងថយទៅក្រោយសិន ចាំយើងដើរទៅដល់ចុងស្ពានកាលណា សឹមអ្នកឯងដើរទៅចុះៗ ពពែ១ ទៀតថាយើងឯងមានការជាបន្ទាន់ ត្រូវតែអ្នកឯងថយទៅក្រោយសិន ចាំយើងដើរទៅដល់ចុងស្ពានកាលណាសឹមអ្នកឯងដើរទៅចុះៗ ពពែទាំងពីរសឹងពុំព្រមថយក្រោយដូចគ្នា កាន់មានះរៀង

ខ្លួនក៏បោលសំរុកដល់គ្នារុញទៅរុញមក ដោយកំលាំងទោសោមោហោ បាំងបិទឥតប្រាជ្ញានឹងសម្របគ្នា ដល់គ្នាធ្លាក់អំពីស្ពានទៅក្នុងទឹកទាំងពីរតួ បាបក្តីវេទនាដោយធ្លាក់ទឹកមានអាការផ្សេងៗ។

រឿងនេះ បានគតិដូចបុគ្គលដែលវិវាទគ្នាដណ្តើមឈ្នះរៀងខ្លួនចុះក្នុងក្បួនបុរាណថា ខឹងកើតខាតមានដំកាត់ឈើឆោត មានក្តីក្រោធក្រោយក្រៀមមុខខំសំរុកធ្លាក់ទឹក ដូចនិទានពពែទាំងពីរនោះឯង គួរចូលចិត្តចុះ។

**ចប់តម្រារុញមិនរាជាគតិទី ២០។**

## និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានសត្វរាជសីហ៍១ ចុះទៅផឹកទឹកស្រះកាលនោះមានសត្វកង្កែប១ នៅក្នុងស្រះបានឃើញរាជសីហ៍ចុះមកផឹកទឹកដូច្នោះក៏ស្រែកកំហែងទៅថា "ឪយរាជសីហ៍ ហេតុអ្វីចៅមកលួចផឹកទឹកយើងចៅសុំនរនាហះ ស្រះនេះជាស្រះរបស់យើងគួរតែគំនាបយើងជាម្ចាស់ស្រះខ្លួហអេះ នេះឯងព្រហើនកោងមកផឹកមិនសុំយើងជាម្ចាស់ឡើយ"។ រាជសីហ៍ឮកង្កែបពោលមកដូច្នោះក៏ទោសោខ្លាំងទើបតទៅវិញថា "ឪយអាកង្កែបតូចប្រចមក់ស្រះ



នេះម៉ែឪអាឯងចែកមកឬទើបបានអាឯងមកពោលថាខ្លួនជាម្ចាស់ស្រះ ស្រះនេះហៅជាតស្រះ គឺស្រះកើតឯងតាំងពីរព្រេងមក ជាស្រះសម្រាប់ពួកសត្វចតុប្បាទទ្វេបាទនឹងមនុស្សទាំងឡាយគេតែអាស្រ័យ នេះហេតុអ្វី អាឯងមកពោលកំហែងអញ ថាអញមិនគំនាប់សុំអាឯងនោះ អញចាំបាច់សុំទានអាឯងធ្វើអ្វី អាឯងជាម្ចាស់កាលណា នែអាកង្កែបអែមនៅគុម្ពក អាមិនស្គាល់ឫទ្ធិចេស្តាអញជាស្តេចលើក្បាលអាឯងទេឬ?។

កង្កែបតបថា "ឪយរាជសីហ៍ ឯងអួតថាខ្លួនជាស្តេចៗមែនហើយ តែជាស្តេចលើសត្វចតុប្បាទខាងជើងគោក ឯអញនេះសោត ក៏ជាស្តេចលើសត្វខាងជើងទឹកឯឫទ្ធិចេស្តា អាឯងក៏មិនលើសលែងគ្នា អញក៏ពុំកោតក្រែងឫទ្ធិអំណាចអាឯងប៉ុន្មានឬអាអាឯងឫទ្ធិសម្រែកស្រែកឲ្យសត្វទាំងឡាយ ឮបែកក្រជៀកស្លាប់នោះ ត្រង់សត្វទាំងឡាយ វាឆោតនាំគ្នាកោតខ្លាចសម្រែករាជសីហ៍ទូទៅ ត្រង់រូបអញ១ នេះមិនឆោតមិនទៅកោតខ្លាចសម្រែកអានោះទេ អាចង់ស្រែកយ៉ាងណាក៏អញមិនព្រឺម"។ ឯរាជសីហ៍បានឮកង្កែបពោលពាក្យឥតក្រែងដូច្នោះ ក៏គិតថាអញនឹងបញ្ចេញនូវសម្រែកឲ្យអាសត្វកង្កែប

នេះវាស្លាប់ក្នុងកាលឥឡូវនេះឯង គិតហើយរាជសីហ៍ក៏ស្រែក ដោយឫទ្ធិយ៉ាងខ្លាំងឡើយ ៗ ឯកង្កែបកាលរាជសីហ៍ស្រែកនោះ វាក៏លោតចាកស្លឹកឈូកមុជចុះទៅក្នុងទឹក លុះសង្រែមករាជសីហ៍ស្ងប់បាត់ហើយ វាក៏ងើបឡើងទំលើស្លឹកឈូកវិញ ហើយពោលឡកទៅថា "អ៊ឺយរាជសីហ៍ឯងស្រែកអម្បាញ់មិញនេះ ឮមិនស្មើនឹងផោមអញផងចូរឯងស្រែកម្តងទៀតទៅមើល" ៗ

ឯរាជសីហ៍ទោសាខ្លាំង ក៏តាំងស្រែកឡើងលើសមុនដើម្បីឲ្យកង្កែបស្លាប់ ឯកង្កែបក៏មុជចុះទៅក្នុងទឹកទៀត លុះស្ងប់សព្ទរាជសីហ៍កាលណា វាក៏ងើបឡើងទំលើស្លឹកឈូកហើយនាំឡកចំអកឲ្យរាជសីហ៍ ដោយប្រការផ្សេងៗ ៗ ឯរាជសីហ៍ក៏រឹងរឹតតែខឹងខ្លាំង តាំងប្រឹងស្រែកខ្លាំងឡើង ទាល់តែប្រេះបែកបំពង់កដួលចុះដល់នូវក្ដីមរណកាលក្នុងកាលនោះហោង ៗ ឯកង្កែបឃើញរាជសីហ៍ស្លាប់ដូច្នោះ ក៏ត្រេកអរដោយសមសេចក្ដីប្រាថ្នារបស់ខ្លួន ៗ

រឿងនេះ បានគតិបុគ្គលទោសាក្រោធមិនគិតអាងឥទ្ធិឫទ្ធិឥតប្រាជ្ញា មិនពិចារណាឲ្យយល់ហេតុនឹងអន្តរាយខ្លួនទៅខាងមុខ គិតតែថាខ្លួនឯងធំ ឯងមានអំណាច កើតមាក់ងាយមើលងាយអ្នក



តូចវិនាសខ្លួនដូចសត្វរាជសីហ៍នោះហោង ៗ

**ចប់តម្រាទោសោគតសតិសម្បជញ្ញៈទី ២១។**

មានសត្វទន្សាយ១ ដើរទៅបានជួបនឹងកូនខ្លាធំពីរនៅខាងគុម្ពឈើ ទើបសួរទៅថា "អ៊ឺយកូនខ្លា ថ្ងៃនេះម៉ែឯងទៅឯណាហើយ" ៗ កូនខ្លាទាំងពីរក៏ប្រាប់ថាម៉ែយើងពុំនៅទេគាត់ចេញទៅរកស៊ីពីព្រឹកមិញហើយ" ៗ ឯទន្សាយក៏និយាយថា "អញមកនេះបើម៉ែឯងនៅអញនឹងល្បងប៉ោលថ្មីអញមើលម្ដង" ថាហើយទន្សាយ ក៏ដើរចេញទៅដល់ព្រៃស៊ុមទ្រុម មានវល្លិត្អើកនោះឯង ៗ ថ្លែងឯមេខ្លា ដល់ពេលល្ងាចស្រទន់ក៏ត្រឡប់មកកាន់សំបុកកូនខ្លួន ដល់ហើយកូនទាំងពីរប្រាប់ថា "ម៉ែអើយថ្ងៃមិញនេះ អាទន្សាយវាមកពោលពាក្យអាសូរោះចាក់ដោតដល់ម៉ែឯង វាថាបើម៉ែឯងនៅនេះ វានឹងល្បងប៉ោលថ្មីវាមើលម្ដង" ៗ មេខ្លាឮដូច្នោះក៏កើត ទោសាក្រោធតទន្សាយជេរថាខ្មោចអាសត្វទន្សាយអប្រិយ គួរអ្វីមកស្ដីពាក្យចំអាសឲ្យអញយ៉ាងនេះ បើដូច្នេះនឹងអត់ឲ្យវាឯណាក៏បាន គួរទៅតាមប្រហារវាឲ្យបង់ជីវិត គិតហើយមេខ្លាលាកូនទាំងពីរចេញចាកទី ចរលីទៅតាមទន្សាយ លុះទៅដល់ព្រៃស៊ុមទ្រុមលបគន់

មើលបានឃើញទន្សាយដេកនៅនោះ មេខ្លាក៏ស្ទុះទៅដោយកំលាំងទោសោដើម្បីនឹងចាប់ទន្សាយហែកប្រហារដោយក្រចកជើង។ ឯទន្សាយ ក៏លោតគេចទៅ ខាងក្រោមវល្លិត្អើកផុតក្រញាំជើងខ្លាៗ លោតទៅលើស៊ុមទ្រុម ធ្លាក់ខ្លួនចុះស៊ុមទ្រុមវល្លិទើកវល្លិត្អើកក៏រឹតរុំជុំខ្លួនមេខ្លាជាប់ជើងទាំងមុខទាំងក្រោយ ខំបម្រះឡើងដោយកំលាំង។

ឯទន្សាយឃើញមេខ្លាជាប់វាមដូច្នោះ ក៏ស្ទុះឡើងពីខាងគូធនៃមេខ្លា ធ្វើអាការការលោកិយហើយស្រដីថា ហឹះៗឯងថាចង់ល្បងប៉ោលថ្មីលេងៗ ឥឡូវគេឲ្យឯងល្បងប៉ោលថ្មីទាល់តែបាន ទន្សាយធ្វើអាការផ្ទាលមេខ្លានោះស្រេចហើយ ក៏ស្ទុះចុះរត់ទៅកាន់ទីដទៃហោង។

ឯមេខ្លាកាលទន្សាយរត់ផុតទៅហើយ ក៏ខំទើខ្លួនអំពីវាមស៊ុមទ្រុមនោះ បានហើយក៏ចេញមកមានសេចក្ដីខឹងនឹងទន្សាយមហិមា នឹងទៅតាមចាប់វា ពេលក៏ស្រទន់ទៀបល្ងាចហើយ មេខ្លាក៏វិលត្រឡប់ទៅកាន់សំបុកខ្លួនវិញ ដល់ហើយកូនទាំងពីរក៏សួរថា "ម៉េចទៅម៉ែ អាទន្សាយនោះម៉ែបានពីឃាតវាហើយឬ"។ មេខ្លាប្រាប់ថា "ពីឃាតវាឯណាក៏បាន ម៉ែទៅនេះសិនគេយកកេរ្តិ៍



ខ្មាសទៅឲ្យវាជាម្ដងហើយចុះ ថ្ងៃនេះឯងធ្វើការបរាជ័យចាញ់វា ចាំថ្ងៃក្រោយៗទៀតសឹមកែខ្លួនឲ្យបាន" ថាហើយមេខ្លាក៏ចូលទៅដេកបំបៅកូនក្នុងរូងនោះហោង។

រឿងនេះ បានគតិដូចបុគ្គលខឹងហួសជ្រួសស្ទៀតដល់នូវក្ដីបរាមុខខ្លួនឯងវិញ។ មែនបុគ្គលណាខឹងហួសខឹងខ្លាំងភ្លាំងសតិបញ្ញាហើយ នឹងបានក្ដីក្ដៅក្រហាយលើសមុនៗនោះទៀតទាល់ស្ទៀតដួលខ្លួនឯងវិញ ដូចមេខ្លានេះឯង។

មួយទៀត ក្ដីក្រោធនេះជាភ្លើងមែនបើឆេះទៅក្នុងទីណាហើយ ទីនោះសឹងវិនាសជាប្រាកដបុគ្គលណា កាន់ក្ដីក្រោធខ្លាំងតាំងចិត្តគិតផុតអ្នកដទៃមិនឆេះទៅអ្នកដទៃឯណាទេ ចំពោះឆេះនៅក្នុងរូបបុគ្គលដែលផុតនោះឯង ភ្លើងទោសៈនេះ ដូចមេឃ្មុំទាំងឡាយ តែខឹងខំប្រឹងទិចគេ ឯទ្រនិចឃ្មុំនោះ តែងសណ្ដកបាកគូធ មិនសណ្ដកតែទ្រនិចនោះទេសណ្ដកជាប់ដល់ពោះវៀនផង លោកថាឃ្មុំណាទិចគេ ឃ្មុំនោះអស់ទ្រនិចហើយនឹងតាំងនៅជាមេឃ្មុំវិញពុំបាន សឹងធ្លាក់ជាតិទៅជាមេរបោមអ្នកប្រាជ្ញខ្លះថាឃ្មុំនោះស្លាប់ខ្លួនឯង។

មួយទៀត ការផ្ចាញ់សត្រូវខ្លួនដោយក្ដីក្រោធលោកនិតិថា៖

អក្កោធេន ជិនេ កោធំ

អសាធុ សាធុនា ជិនេ

កទរិយញ្ញា ទានេន

សច្ចេនាលិកភាទីនំ។

អធិប្បាយថា ឈ្នះអ្នកក្រោធដោយក្រឹត្យមិនក្រោធតប ឈ្នះអសប្បុរសប្រកបដោយសប្បុរសឈ្នះកំណាញ់ដោយឲ្យទ្រព្យរបស់ ឈ្នះបុរសទ្បេះទ្បោះដោយពាក្យសត្យ ៗ

មួយទៀត បុគ្គលណាកំចាត់ក្តីក្រោធបាន បុគ្គលនោះផុតក្តីក្តៅក្រហាយ ក្តីសៅសោកបានដូចបទបាលីថា៖

កោធំ វិហិត្វា ន កទាចិ សោចតិ

មក្ខប្បហានំ ឥសយោ វណ្ណយន្តិ

សព្វេសំ ផរុសវចនំ ខមេថ

តំខន្តី ឧត្តមមាហុ សន្តោ។

អធិប្បាយថា ជនឯណាកំចាត់ក្តីក្រោធបានជននោះគ្មានសៅសោកក្នុងលោកិយ ព្រះឥសីសរសើរ អ្នកគប្បី លះបង់ក្តីលុបគុណកបសត្យា អ្នកឯណាអាចអត់ផរុវាទ មិនរលាតដោយ



ពាក្យបេសុញ្ញា សប្បុរសសរសើរអ្នកនោះណា កបខន្តីតិក្ខាជាឧត្តម ៗ

ចប់តម្រាខឹងហួសជ្រួសផ្តាសបង់ខ្មាសខ្លួនឯងទី ២២។

ចប់ភាគទី ៥ តែប៉ុណ្ណោះ។

---